00748565

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Préliminaire

លេខ/No: **D11/2/4/4**

*តាមនាមប្រជារាស្ត្រខ្មែរ និងតាមនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ*

**សំណុំរឿងព្រហ្មទណ្ឌលេខ:** ០០៣/០៧-០៩-២០០៩-អវតក/កសចស(អបជ០២)

**ចំពោះមុខ:**
ចៅក្រម ប្រាក់ គីមសាន ប្រធាន
ចៅក្រម Rowan DOWNING
ចៅក្រម ន៉ីយ ថុល
ចៅក្រម Katinka LAHUIS
ចៅក្រម ហួត វុទ្ធី

**កាលបរិច្ឆេទ:** ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ២០១១

---

សាធារណៈ (សំណៅកោសលុប)

**សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ ទាក់ទិននឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាសម្រេចស្តីពីការទទួលយកអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីលោក រ៉ូប៊ឺត ហាមីល (ROBERT HAMILL)**

---

**សហព្រះរាជអាជ្ញា**
ជា លាង
Andrew CAYLEY

**សហមេធាវីអ្នកដាក់ពាក្យតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី**
សំ សុគង់
Lyma Thuy NGUYEN

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 24/10/2011
ម៉ោង (Time/Heure): 14:45
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

**អង្គបុរេជំនុំជម្រះ** នៃអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា ("អ.វ.ត.ក") បានទទួល "បណ្ដឹងឧទ្ធរណ៍ប្រឆាំងដីកាសម្រេចស្ដីពីការទទួលយកអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី លោក រ៉ូប៊ឺត ហាមីល (Robert Hamill) (ឯកសារលេខ D11/2/3) (សំណុំរឿង ០០៣ និង ០០៤)" ដែលបានដាក់ដោយសហមេធាវី នៅថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០១១ ("បណ្ដឹងឧទ្ធរណ៍")[១]។

## I. ប្រវត្តិនីតិវិធី និងសារណា

១. នៅថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០០៩ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់ជាសម្ងាត់នូវ "ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទីពីរ [redacted]" ("ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទីពីរ")[២] ជូនទៅសហចៅក្រមស៊ើបអង្កេត ដោយស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេតបើកកិច្ចស៊ើបសួរសម្រាប់សំណុំរឿង ០០៣។

២. នៅថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០១១ លោក រ៉ូប៊ឺត ហាមីល (Robert Hamill) ("ម្ចាស់បណ្ដឹងឧទ្ធរណ៍") បានដាក់ពាក្យសុំទៅអង្គភាពគាំពារជនរងគ្រោះ ("VSS") ដោយស្នើសុំឱ្យទទួលស្គាល់គាត់ជាដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង ០០៣ និង ០០៤ នៅ អ.វ.ត.ក។ នៅក្នុងពាក្យសុំរបស់គាត់ ម្ចាស់បណ្ដឹងឧទ្ធរណ៍បានអះអាងថា គាត់បានទទួលរងព្យសនកម្មជាផលវិបាកផ្ទាល់ពីបទឧក្រិដ្ឋដែលត្រូវបានប្រព្រឹត្តទៅលើបងប្រុសរបស់គាត់ឈ្មោះលោក ឃែរី ហាមីល (Kerry HAMILL) ដែលត្រូវបានចាប់ខ្លួននៅខែ សីហា ឆ្នាំ ១៩៧៨ ដោយកងទ័ពជើងទឹកកម្ពុជាប្រជាធិបតេយ្យ និងត្រូវបានបញ្ជូនទៅមន្ទីរ ស២១ ដែលនៅទីនោះគាត់ត្រូវបានគេឃុំឃាំង សួរចម្លើយ ធ្វើ

---

[១] បណ្ដឹងឧទ្ធរណ៍ប្រឆាំងដីកាសម្រេចស្ដីពីការទទួលយកអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីលោក រ៉ូប៊ឺត ហាមីល (Robert Hamill) (ឯកសារលេខ D11/2/3) (សំណុំរឿង ០០៣ និង ០០៤), ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០១១, ឯកសារលេខ D11/2/4/2 ("បណ្ដឹងឧទ្ធរណ៍")។

[២] សេចក្ដីជូនដំណឹងរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្ដីទីអំពីការដាក់ឯកសារស្ដីពី ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទីពីរ, ចុះថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០០៩, ឯកសារលេខ D1/1។

ទារុណកម្ម និងយកទៅសម្លាប់[៣]។ ពាក្យសុំរបស់គាត់ត្រូវបានអង្គភាពគាំពារជនរងគ្រោះដាក់ជូនសហចៅក្រមស៊ើបអង្កេតនៅថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០១១[៤]។

៣. នៅថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១១ នៅជាមួយថ្ងៃដែលកិច្ចស៊ើបសួរក្នុងសំណុំរឿង ០០៣ បានបញ្ចប់នោះ សហចៅក្រមស៊ើបអង្កេតបានចេញ "ដីកាសម្រេចលើការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីលោក រ៉ប ហាមីល (Rob Hamill)" ("ដីកាដែលត្រូវបានជំទាស់") ដោយប្រកាសថា ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍មិនអាចទទួលយកបាន ដោយមូលហេតុថា "អ្នកដាក់ពាក្យសុំមិនបានបង្ហាញថា គាត់បានទទួលរងព្យសនកម្មផ្លូវចិត្តដូចបានចោទប្រកាន់ ដែលជាផលវិបាកដោយផ្ទាល់នៃការស្លាប់បងប្រុសគាត់ទេ"[៥]។ សហមេធាវីអះអាងថា ម្ចាស់បណ្តឹងឧទ្ធរណ៍បានទទួលដីកាដែលត្រូវបានជំទាស់ តាមប្រៃសណីយ៍នៅអាសយដ្ឋានរបស់គាត់នៅប្រទេសនូវែលសេឡង់ នៅថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ២០១១ តែសហមេធាវីពុំបានទទួលការជូនដំណឹងស្តីពីដីកាសម្រេចនេះទេ[៦]។

៤. នៅថ្ងៃទី ៩ ខែ ឧសភា ឆ្នាំ ២០១១ សហព្រះរាជអាជ្ញាអន្តរជាតិបានចេញសេចក្តីថ្លែងការណ៍ជាសាធារណៈមួយ ដោយបញ្ចេញឲ្យដឹងនូវវិសាលភាពនៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរទីពីរ[៧]។

---

[៣] ទំព័របែបបទព័ត៌មានអំពីជនរងគ្រោះ, ចុះថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១១ ដែលបានដាក់នៅអង្គភាពគាំពារជនរងគ្រោះ នៅថ្ងៃទី ១២ ខែ មេសា ឆ្នាំ ២០១១, ឯកសារលេខ D11/2 ("ពាក្យសុំ")។

[៤] ពាក្យសុំ, ដែលត្រូវបានបោះត្រានៅថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០១១ ដោយមន្ត្រីគ្រប់គ្រងសំណុំរឿង តែបានបញ្ចូលទៅក្នុងសំណុំរឿងនៅថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១១ ដូចមានបញ្ជាក់នៅក្នុងទម្រង់បែបបទស្តីពីការដាក់ឯកសារ។

[៥] ដីកាដែលត្រូវបានជំទាស់, កថាខណ្ឌ ៥។

[៦] បណ្តឹងឧទ្ធរណ៍, កថាខណ្ឌ ៣។

[៧] សេចក្តីថ្លែងការណ៍ដែលបានធ្វើឡើងដោយសហព្រះរាជអាជ្ញាអន្តរជាតិទាក់ទិននឹងសំណុំរឿង ០០៣, ចុះថ្ងៃទី ៩ ខែ ឧសភា ឆ្នាំ ២០១១។ សេចក្តីថ្លែងការណ៍នេះត្រូវបានបង្គាប់ឲ្យដកវិញ ដោយដីកាចេញដោយសហចៅក្រមស៊ើបអង្កេត ("ដីកាសម្រេចស្តីអំពីសេចក្តីប្រកាសព័ត៌មានជាសាធារណៈរបស់សហព្រះរាជអាជ្ញាអន្តរជាតិទាក់ទិននឹងសំណុំរឿង ០០៣, ចុះថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១១, ឯកសារលេខ D14") និងត្រូវបានប្តឹងឧទ្ធរណ៍ដែលបច្ចុប្បន្នកំពុងពិនិត្យ និងសម្រេចដោយអង្គបុរេជំនុំជម្រះ ("បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំង "ដីកាសម្រេចស្តីអំពីសេចក្តីប្រកាសព័ត៌មានជាសាធារណៈរបស់សហព្រះរាជអាជ្ញាអន្តរជាតិទាក់ទងនឹងសំណុំរឿង ០០៣", ចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១១, ឯកសារ D14/1/1)។

៥. នៅថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០១១ សហមេធាវីបានដាក់សេចក្តីជូនដំណឹងស្តីពីបណ្តឹងឧទ្ធរណ៍ទៅសហចៅក្រមស៊ើបអង្កេត[8]។ ក្នុងការចុះបញ្ជីបណ្តឹងឧទ្ធរណ៍ ក្រឡាបញ្ជីនៃការិយាល័យសហចៅក្រមស៊ើបអង្កេតបានអះអាងថា សហមេធាវីមិនទាន់ត្រូវបានទទួលស្គាល់ដោយសហចៅក្រមស៊ើបអង្កេតនៅឡើយទេ។

៦. នៅថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០១១ សហមេធាវីបានដាក់ "សំណើសុំពន្យារកាលបរិច្ឆេទកំណត់សម្រាប់ដាក់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេច ស្តីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ Robert Hamill ក្នុងពេលកំពុងរង់ចាំការអនុញ្ញាតឲ្យចូលមើលសំណុំរឿង ០០៣ និង ០០៤" ("សំណើសុំសិទ្ធិពិនិត្យសំណុំរឿង") ដោយបានស្នើសុំថា អង្គបុរេជំនុំជម្រះគួរប្រើប្រាស់ឆន្ទានុសិទ្ធិរបស់ខ្លួន ក្នុងការពន្យារកាលបរិច្ឆេទកំណត់ក្នុងការដាក់បណ្តឹងឧទ្ធរណ៍ទៅតាមពេលវេលាសមរម្យ បន្ទាប់ពីអ្នកតំណាងតាមផ្លូវច្បាប់របស់ម្ចាស់បណ្តឹងឧទ្ធរណ៍បានទទួលសិទ្ធិពិនិត្យសំណុំរឿង ឬម្យ៉ាងវិញទៀត អង្គបុរេជំនុំជម្រះគួរអនុញ្ញាតឲ្យពួកគេអាចដាក់សំអាងហេតុតាមផ្លូវច្បាប់ និងអង្គហេតុបន្ថែមទៀត នៅតាមពេលវេលាសមរម្យ បន្ទាប់ពីបានទទួលសិទ្ធិពិនិត្យសំណុំរឿងរួច[9]។ សហមេធាវីបានចោទប្រកាន់ថា ថ្វីត្បិតតែពួកគាត់បានដាក់សំណើកាលពីថ្ងៃទី ១ ខែ ឧសភា ឆ្នាំ ២០១១ ទៅសហចៅក្រមស៊ើបអង្កេតក៏ដោយ ក៏ពួកគេពុំទាន់ទទួលបានការអនុញ្ញាតសិទ្ធិពិនិត្យសំណុំរឿងនៅឡើយទេ[10]។

៧. នៅថ្ងៃដដែលនោះ សហមេធាវីបានដាក់បណ្តឹងឧទ្ធរណ៍ ដោយបានលើកឡើងនូវមូលដ្ឋានមួយចំនួននៃបណ្តឹងឧទ្ធរណ៍ដូចជា៖ i) សហចៅក្រមស៊ើបអង្កេតបានរំលោភវិធាន ២១(គ) នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក ("វិធានផ្ទៃក្នុង") "ដើម្បីធានានូវអំពីសច្ចភាពផ្លូវច្បាប់ និងកិច្ចដំណើរការនីតិវិធីប្រកបដោយតម្លាភាព" ដោយបដិសេធមិនទទួលយកម្ចាស់បណ្តឹងឧទ្ធរណ៍ដោយផ្អែកលើមូលដ្ឋានថា គាត់ជា "ជនរងគ្រោះប្រយោល" ii) សហចៅក្រមស៊ើបអង្កេតបានរំលោភវិធាន ២៣*ស្ទួន* (១)(ខ) នៃវិធានផ្ទៃក្នុង និងមាត្រា៣.២(គ) នៃសេចក្តីណែនាំអនុវត្តស្តីពីការចូលរួមរបស់ជនរងគ្រោះ

---

[8] កំណត់ហេតុបណ្តឹងឧទ្ធរណ៍, ឯកសារលេខ D11/2/4។

[9] សំណើសុំពន្យារកាលបរិច្ឆេទកំណត់សម្រាប់ការដាក់បណ្តឹងឧទ្ធរណ៍ ជំទាស់នឹងដីកាស្តីពីភាពអាចទទួលយកបានចំពោះពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់លោក Robert Hamill ក្នុងពេលកំពុងរង់ចាំការអនុញ្ញាតឲ្យចូលមើលសំណុំរឿងក្តី ០០៣ និង ០០៤ ("សំណើសុំសិទ្ធិពិនិត្យសំណុំរឿង"), ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០១១, ឯកសារលេខ D11/2/4/1, កថាខណ្ឌ ៥។

[10] សំណើសុំសិទ្ធិពិនិត្យសំណុំរឿង, កថាខណ្ឌ ៤។

iii) សហចៅក្រមស៊ើបអង្កេតបានរំលោភវិធាន ៥៦ និងវិធាន ២១ នៃវិធានផ្ទៃក្នុង ដែលជាគោលការណ៍មូលដ្ឋាននៃសិទ្ធិរបស់ជនរងគ្រោះ និងគោលការណ៍ជាសារវ័ន្តនៃភាពយុត្តិធម៌ក្នុងដំណើរការនីតិវិធីដែលត្រូវផ្តល់ព័ត៌មានដល់សាធារណជនអំពីសំណុំរឿង ០០៣ និង សំណុំរឿង ០០៤ iv) ការខកខានមិនបានផ្តល់សំអាងហេតុសមរម្យទាក់ទិននឹងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី របស់ម្ចាស់បណ្តឹងឧទ្ធរណ៍ក្នុងសំណុំរឿង ០០៤ នោះ សហចៅក្រមស៊ើបអង្កេតបានរំលោភវិធាន ២១ នៃវិធានផ្ទៃក្នុង ពាក់ព័ន្ធនឹងគោលការណ៍ជាសារវ័ន្តនៃភាពយុត្តិធម៌ ក្នុងដំណើរការនីតិវិធីដែលត្រូវផ្តល់សំអាងហេតុសម្រាប់សេចក្តីសម្រេចណាមួយ v) សហចៅក្រមស៊ើបអង្កេតបានរំលោភវិធាន ១៤(១) និង វិធាន ៥៥(៥) នៃវិធានផ្ទៃក្នុង មាត្រា ១០ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និង មាត្រា ៥ (២) និង (៣) នៃកិច្ចព្រមព្រៀង ដោយខកខានមិនបានបើកកិច្ចស៊ើបសួរក្នុងសំណុំរឿង ០០៣ ឲ្យបានសមរម្យ និងឯករាជ្យ vi) ដោយការបដិសេធមិនទទួលយកបណ្តឹងរដ្ឋប្បវេណីរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ សហចៅក្រមស៊ើបអង្កេតបានធ្វើឲ្យរាំងស្ទះដល់ដំណើរការយុត្តិធម៌នៅ អ.វ.ត.ក ដែលជនរងគ្រោះក៏ដូចជាសហគមន៍អន្តរជាតិមានរំពឹងថានឹងបានទទួល ហើយទង្វើបែបនេះជាសារមួយបង្ហាញថា មានការកើតឡើងនូវអំពើនិទ្ទណ្ឌភាព ដែលជាការរំលោភដល់គោលបំណងចម្បងរបស់ អ.វ.ត.ក ដូចមានចែងក្នុងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក។

៨. ដោយកត់សម្គាល់ថា នៅក្នុងផ្នែកអាជ្ញាបញ្ញានៃដីកាដែលត្រូវបានជំទាស់ "បានបដិសេធមិនទទួលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី [របស់ម្ចាស់បណ្តឹងឧទ្ធរណ៍] ក្នុងសំណុំរឿង ០០៤"[១១] សហមេធាវីអះអាងថា ទាំងសហមេធាវីខ្លួនឯង ទាំងម្ចាស់បណ្តឹងឧទ្ធរណ៍ក្តីសុទ្ធតែមិនបានទទួលដីកាដែលចេញក្នុងសំណុំរឿង ០០៤ ដូចគ្នា ទោះបីពួកគាត់បានព្យាយាមជាច្រើនលើកច្រើនគ្រាដើម្បីទទួលបានដីកានេះក៏ដោយ[១២]។ ជាលទ្ធផល ពួកគាត់បានដាក់បណ្តឹងឧទ្ធរណ៍ក្នុងសំណុំរឿង ០០៣ និង ០០៤ តែមួយជាមួយគ្នា ដែលមានបំណងគ្របដណ្តប់លើសំណុំរឿងទាំងពីរតែម្តង។ អង្គបុរេជំនុំជម្រះសង្កេតឃើញថា សាលដីកាសម្រេចនេះដោះស្រាយចំពោះបណ្តឹងឧទ្ធរណ៍ដែលពាក់ព័ន្ធនឹងដីកាដែលត្រូវបានជំទាស់ក្នុងសំណុំរឿង ០០៣ តែមួយប៉ុណ្ណោះ ហើយក៏សង្កេតឃើញផងដែរថា អង្គជំនុំជម្រះនឹងចេញសាលដីកាសម្រេចមួយទៀត ទាក់ទិននឹងពាក្យសុំរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ក្នុងសំណុំរឿង ០០៤។

[១១] ដីកាដែលរងការជំទាស់, កថាខណ្ឌទីពីរនៃ ផ្នែកសម្រេចសេចក្តី, បណ្តឹងឧទ្ធរណ៍, កថាខណ្ឌ ៤។

[១២] បណ្តឹងឧទ្ធរណ៍, កថាខណ្ឌ ៤ និង ៦។



អង្គបុរេជំនុំជម្រះ
PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE
E.C.C.C. * C.E.T.C.

៩. នៅថ្ងៃទី ៦ ខែ កក្កដា ឆ្នាំ ២០១១ សហចៅក្រមស៊ើបអង្កេតបានដាក់សំណើមួយសុំកែប្រែសំណៅជាភាសាអង់គ្លេសនៃដីកាដែលត្រូវបានជំទាស់[១៣] ហើយនៅថ្ងៃទី ៧ ខែ កក្កដា ឆ្នាំ ២០១១ សហចៅក្រមស៊ើបអង្កេតបានដាក់ដីកាដែលត្រូវបានជំទាស់សំណៅថ្មីជាភាសាអង់គ្លេស ទៅក្នុងសំណុំរឿងជំនួសសំណៅចាស់ ចុះថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១១ ("ដីកាកែប្រែ")[១៤]។ នៅថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០១១ សំណើសុំកែប្រែមួយស្រដៀងគ្នានេះត្រូវបានធ្វើឡើងដោយអង្គភាពបកប្រែភាសាចំពោះ "ការបកប្រែជាភាសាខ្មែរ" នៃដីកាដែលត្រូវបានជំទាស់ ដែលត្រូវបានបញ្ចូលក្នុងសំណុំរឿងនូវការបកប្រែថ្មីមួយជំនួសវិញ ចុះថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១១។

១០. នៅថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០១១ អង្គបុរេជំនុំជម្រះបានជូនដំណឹងដល់ភាគីថា ខ្លួននឹងសម្រេចទៅលើសំណើសុំសិទ្ធិពិនិត្យសំណុំរឿង នៅពេលដោះស្រាយខ្លឹមសារនៃបណ្តឹងឧទ្ធរណ៍[១៥]។

១១. ពុំមានចម្លើយតបណាមួយត្រូវបានដាក់ចំពោះបណ្តឹងឧទ្ធរណ៍នេះទេ។

## II. ការបញ្ចេញមតិយោបល់ និង សេចក្តីសន្និដ្ឋាន

១២. ទោះបីមានការខិតខិតប្រឹងប្រែងយ៉ាងណាក្តី អង្គបុរេជំនុំជម្រះមិនអាចសម្រេចបានសំឡេងគាំទ្រជាវិជ្ជមានពីចៅក្រមបួនរូបយ៉ាងតិច ដែលចាំបាច់ដើម្បីអាចចេញសេចក្តីសម្រេចមួយលើសំណើសុំសិទ្ធិពិនិត្យសំណុំរឿង ឬលើបញ្ហានានាដែលបានលើកឡើងនៅក្នុងបណ្តឹងឧទ្ធរណ៍បានទេ ឬ សូម្បីតែវិធីសាស្ត្រក្នុងការដោះស្រាយទៅនឹងបណ្តឹងឧទ្ធរណ៍នេះក៏មិនអាចសម្រេចបានដែរ។ ដោយហេតុថាវិធាន ៧៧(១៤) នៃវិធានផ្ទៃក្នុងចែងថា សេចក្តីសម្រេចរបស់អង្គជំនុំជម្រះត្រូវមានសំអាងហេតុនោះ មតិយោបល់ផ្សេងៗរបស់ចៅក្រមអង្គជំនុំជម្រះមានភ្ជាប់នឹងសេចក្តីពិចារណាទាំងនេះ។

[១៣] ឯកសារលេខ D11/2/3/កែប្រែ១។

[១៤] ដីកាកែប្រែមានលេខយោងដូចគ្នាបេះបិទទៅនឹងដីកាដែលត្រូវបានជំទាស់ដែរ។

[១៥] ការជូនដំណឹងដល់ភាគី ដែលពាក់ព័ន្ធនឹងសំណើរបស់មេធាវីសុំពន្យារកាលបរិច្ឆេទកំណត់សម្រាប់ការដាក់បណ្តឹងឧទ្ធរណ៍ក្នុងពេលកំពុងរង់ចាំការអនុញ្ញាតឲ្យចូលមើលសំណុំរឿងក្តី, ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០១១, ឯកសារលេខ D11/2/4/3។

១៣. ដោយសារថា អង្គបុរេជំនុំជម្រះមិនបានសម្រេចទៅលើបណ្តឹងឧទ្ធរណ៍នេះ វិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុងចែងថា ដីកាដែលត្រូវបានជំទាស់នេះត្រូវបានតម្កល់ទុកជាបានការ។ សនិទានភាពដូចគ្នានេះក៏ត្រូវយកមកអនុវត្តចំពោះសំណើសុំសិទ្ធិពិនិត្យសំណុំរឿងដែរ ពោលគឺសំណើនេះមិនអាចត្រូវបានទទួលយកទេ ដោយសារមិនអាចសម្រេចបានសំឡេងគាំទ្រវិជ្ជមានពីចៅក្រមបួនរូបយ៉ាងតិច។

## III. **ការសម្រេចសេចក្តី**

**អាស្រ័យហេតុនេះ អង្គបុរេជំនុំជម្រះសូម:**

**ប្រកាសជាឯកច្ឆន្ទថា** អង្គបុរេជំនុំជម្រះមិនអាចរកសំឡេងគាំទ្រជាវិជ្ជមានពីចៅក្រមបួនរូបយ៉ាងតិច ទៅលើសំណើសុំសិទ្ធិពិនិត្យសំណុំរឿងនេះទេ។

**ប្រកាសជាឯកច្ឆន្ទថា** អង្គបុរេជំនុំជម្រះមិនអាចរកសំឡេងគាំទ្រជាវិជ្ជមានពីចៅក្រមបួនរូបយ៉ាងតិច ទៅលើសេចក្តីសម្រេចស្តីពីបណ្តឹងឧទ្ធរណ៍នេះទេ។

ដោយអនុលោមតាមវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង ភាគីមិនមានលទ្ធភាពប្តឹងតវ៉ាទេ។

**ភ្នំពេញ, ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១១**

**ប្រធាន** **អង្គបុរេជំនុំជម្រះ**

**ប្រាក់ គឹមសាន** **Rowan DOWNING** **ន័យ ចុល** **Katinka LAHUIS** **ហួត វុទ្ធី**

ចៅក្រម ប្រាក់ គឹម សាន ចៅក្រម ន័យ ចុល និង ចៅក្រម ហួត វុទ្ធី សូមភ្ជាប់មតិយោបល់របស់ខ្លួន។

ចៅក្រម Downing និង ចៅក្រម Lahuis សូមភ្ជាប់មតិយោបល់របស់ខ្លួន។

០០៣/០៧-០៩-២០០៩-អវតក/កសចស (អបដ០២)

លេខ/No: D11/2/4/4

# យោបល់របស់ចៅក្រម ប្រាក់ គីមសាន ចៅក្រម ន័យ ថុល និងចៅក្រម ហួត វុទ្ធី

១. ក្នុងបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេច ស្ដីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់លោក Robert Hamill (D11/2/3) ("បណ្ដឹងឧទ្ធរណ៍")[១] លោកបានបញ្ជាក់ថា លោកបានផ្ដល់សក្ខីកម្ម នៅក្នុងសំណុំរឿង ០០១ ប្រឆាំងនឹងកាំង ហ្កេកអ៊ាវ (ហៅ ឌុច) ដែលជាប្រធានមន្ទីរស ២១ អំពីជោគវាសនារបស់បងប្រុសគាត់ឈ្មោះ Kerry Hamill ដែលគាត់ត្រូវបានឃុំឃាំង សួរចម្លើយ ធ្វើទារុណកម្ម និងសម្លាប់នៅ ស ២១[២] ។ នៅក្នុងទម្រង់បែបបទស្ដីពីពត៌មានជនរងគ្រោះរបស់ម្ចាស់បណ្ដឹងឧទ្ធរណ៍(11-VSS-00002) លោកបានរៀបរាប់អង្គហេតុថា នៅថ្ងៃទី ១៣ ខែសីហា ឆ្នាំ ១៩៧៨ បងប្រុសម្ចាស់បណ្ដឹងឧទ្ធរណ៍ឈ្មោះ Kerry George Hamill ជាមេក្រុម និងជាសហកម្មសិទ្ធិករទូកក្ដោងប្រវែង ២៨ ហ្វ៊ីត ឈ្មោះ Foxy Lady ជាមួយសហកម្មសិទ្ធិករម្នាក់ទៀត ជាជនជាតិកាណាដា ឈ្មោះ Stuart Glass និងអ្នកដំណើរម្នាក់ជាជាតិអង់គ្លេសឈ្មោះ John Dewhirst បានឈប់សុំចតនៅលើឆកមួយនៃកោះតាង ដែលមានចម្ងាយ ៥០ គីឡូម៉ែត្រ ពីឆ្នេរភាគនិរតីក្រុងព្រះសីហនុ។ នៅល្ងាចនោះ មានការបាញ់សំដៅទៅលើទូកក្ដោង Foxy Lady និងនាវិកទាំងអស់។ Stuart Glass ដែលនៅលើដំបូល ត្រូវបានគេបាញ់ត្រូវ។ Kerry នៅលើដំបូលដែរក៏ជួយលើក Stuart ដាក់លើទូកសង្គ្រោះ។ John Dewhirst ដែលនៅក្រោមដំបូលនាពេលបាញ់នោះក៏ឡើងមកលើ រួចគេចខ្លួនជាមួយ Kerry ដោយលោតចូលទៅក្នុងទឹក[៣]។ បន្ទាប់មកទូកខ្មែរក្រហមដែលមានអាវុធ ក៏ចូលទៅចាប់បុរសទាំងពីរនាក់នោះ។ Stuart បានស្លាប់បាត់បង់ជីវិត រួចត្រូវបានបោះចូលក្នុងសមុទ្រ។ បុរសទាំងពីរនាក់នោះ ត្រូវបានគេដាក់ច្រវាក់ជើង និងចងមុខ ហើយបន្ទាប់មកត្រូវបានគេនាំយកទៅឃុំឃាំងក្នុងរោងកុនមួយ នៅក្រុងព្រះសីហនុរយៈពេលមួយ ឬ ពីរថ្ងៃ មុននឹងបញ្ជូនទៅមន្ទីរសន្តិសុខ ស ២១ នៅភ្នំពេញ[៤]។ នៅ ស ២១ បុរសទាំងពីរនាក់ត្រូវបាន គេសួរចម្លើយ និងធ្វើទារុណកម្ម រួមមានការឆក់ខ្សែរភ្លើងផង។ នៅទីបំផុត អ្នកទាំងពីរត្រូវបានគេបង្ខំឲ្យចុះ

---

[១] បណ្ដឹងឧទ្ធរណ៍ របស់លោក Robert Hamill D11/2/4/2។

[២] កថាខណ្ឌទី ២៥ នៃបណ្ដឹងឧទ្ធរណ៍ D11/2/4/2។

[៣] កថាខណ្ឌទី ២៦ នៃបណ្ដឹងឧទ្ធរណ៍ D11/2/4/2។

[៤] កថាខណ្ឌទី ២៧ ៖ នៃបណ្ដឹងឧទ្ធរណ៍ D11/2/4/2។

ហត្ថលេខាលើចម្លើយសារភាព ដោយអះអាងថា ពួកគេជាភ្នាក់ងារសេអ៊ីអា។ ចម្លើយសារភាពទាំងនេះ មិនពិតទាល់តែសោះ[៥]។ នៅក្នុងចម្លើយសារភាពក្លែងក្លាយរបស់ Kerry បានប្រឌិត រឿងរ៉ាវអំពី "ការហ្វឹកហ្វឺនរបស់សេអ៊ីអា" ដោយបញ្ចូលទៅក្នុងហេតុការណ៍ពិតក្នុងជីវិតរបស់គាត់។ Kerry បានប្រើលេខទូរស័ព្ទនៅផ្ទះគ្រួសារ Hamill នាពេលនោះ (៨៧០៨) ជាលេខប្រតិបត្តិការ របស់សេអ៊ីអា គាត់បានរៀបរាប់ថាវរៈសេនីយ៍ឯក Sanders (ម្ចាស់ហាងមាន់បំពង Kentucky Fried Chicken) ជាថ្នាក់លើម្នាក់របស់គាត់ បានរៀបរាប់មិត្តភក្តិច្រើនថា ជាសមាជិកសេអ៊ីអា ដែលជួយ បណ្តុះបណ្តាលគាត់អំពីការស៊ើបការណ៍របស់សេអ៊ីអា ហើយ "លោក S. Tarr" ជាគ្រូបង្រៀនជំនាញ ការថ្លែងជាសាធារណៈ។ តាមពិត S. Tarr ជាឈ្មោះម្តាយលោក គឺអ្នកស្រី Esther តែប៉ុណ្ណោះ[៦]។ ចម្លើយសារភាពរបស់ Kerry ត្រូវបានចុះហត្ថលេខា ប្រហែលពីរខែក្រោយពេលគាត់ត្រូវគេចាប់ខ្លួន ហើយមានការសន្មត់ថាគាត់ត្រូវបានគេសម្លាប់ នៅអំឡុងពេលចុះហត្ថលេខាលើចម្លើយសារភាពនោះឯង។ វិធីសាស្ត្រពិតប្រាកដជាក់ស្តែង ក្នុងការសម្លាប់ Kerry មិនត្រូវបានគេដឹងទេ[៧]។

២. អង្គហេតុដែលអ្នកដាក់ពាក្យសុំលោក Robert Hamill បានលើកឡើង នៅក្នុងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចស្តីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០១១ សុទ្ធតែជាអង្គហេតុដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរទី ១[៨] ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០៧ រួចហើយ គឺ ៖

- សេចក្តីសង្ខេប នៃអង្គហេតុ (កថាខណ្ឌទី១ ដល់ ទី៣៦)។
- ការជម្លៀសដោយបង្ខំ (កថាខណ្ឌទី ៣៧ ដល់ ទី ៤២)។
- ការធ្វើពលកម្មដោយបង្ខំ ស្ថានភាពរស់នៅអមនុស្សធម៌ និងការឃុំខ្លួនដោយខុសច្បាប់ (កថាខណ្ឌទី ៤៣ ដល់ ទី ៤៨)។

---

[៥] កថាខណ្ឌទី ២៨៖ នៃបណ្តឹងឧទ្ធរណ៍ D11/2/4/2 ។

[៦] កថាខណ្ឌទី ២៩ នៃបណ្តឹងឧទ្ធរណ៍ D11/2/4/2 ។

[៧] កថាខណ្ឌទី ៣០ ៖ នៃបណ្តឹងឧទ្ធរណ៍ D11/2/4/2 ។

[៨] ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ លេខ D3

- ការសម្លាប់ ការធ្វើទារុណកម្ម និងការរំលោភបំពានផ្នែករាងកាយ និងផ្លូវចិត្ត ( កថាខណ្ឌទី ៥៩ និង ទី ៥៥ ) តំបន់ភ្នំពេញ។
- តំបន់ស្វយ័ត កំពង់សោម (កថាខណ្ឌទី ៥៩)។
- ភូមិភាគឧត្តរចាស់ ភូមិភាគបូព៌ា។

ព្រមទាំងនៅក្នុងដីកាដំណោះស្រាយនៃសំណុំរឿងលេខ០០២/១៩-០៩-២០០៧/អ.វ.ត.ក/ក.ស.ច.ស[៥]។

៣. ម្យ៉ាងទៀត ចៅក្រមជាតិនៃអង្គបុរេជំនុំជម្រះយល់ឃើញថា អង្គហេតុដែលបានរៀបរាប់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទី២ ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ដែលបង្កើតបានជាសំណុំរឿង ០០៣ សុទ្ធតែអង្គហេតុចាស់ដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរទី ១ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០៧ ។

៤. នៅក្នុងអំឡុងពេលនៃកិច្ចស៊ើបសួររបស់ខ្លួនក្នុងសំណុំរឿង ០០៣ ចាប់ពីពេលបើកការស៊ើបសួរ រហូតដល់ពេលជូនសំណើងពីការបិទការស៊ើបសួរ សហចៅក្រមស៊ើបអង្កេតមិនទាន់បានដាក់ជនណាម្នាក់ឲ្យស្ថិតនៅក្រោមការពិនិត្យនោះទេ មានន័យថា ក្នុងអង្គហេតុដែលសហព្រះរាជអាជ្ញាបញ្ជូនមកសហចៅក្រមស៊ើបអង្កេតតាមរយៈដីកាសន្និដ្ឋានបញ្ជូនឲ្យស៊ើបសួរនោះ គ្មានជនសង្ស័យណាម្នាក់ដែលសហចៅក្រមស៊ើបអង្កេតរកឃើញថា មានតម្រុយជាក់លាក់ និង ស៊ីសង្វាក់ថាបានចូលរួម ក្នុងការប្រព្រឹត្តបទល្មើសដូចដែលបានចោទប្រកាន់នោះទេ។

៥. ដូច្នេះ ការបដិសេធពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ក្នុងដំណាក់កាលនេះមិនធ្វើឲ្យប៉ះពាល់សិទ្ធិរបស់លោក Robert Hamill ឡើយ។ លើសពីនេះទៅទៀត យើងយល់ឃើញថា ៖

៦. តាមគោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់ គឺសហព្រះរាជអាជ្ញាត្រូវធ្វើការវិនិច្ឆ័យលើអង្គហេតុដែលមានលក្ខណៈជាបទល្មើស និង មានជំរើសថា តើត្រូវធ្វើការចោទប្រកាន់ ឬតម្កល់រឿងទុកមិនចាត់ការ ទោះបីអង្គហេតុនោះជាបទល្មើសក៏ដោយ។ តាមគោលការណ៍នេះ សហចៅក្រមស៊ើប

---

[៥] ដីកាដំណោះស្រាយ D427 កថាខណ្ឌទី ២២១ ដល់ ២៨២ និងកថាខណ្ឌទី ៦៤៤ ដល់ ៦៦៦ ។

អង្កេតត្រូវធ្វើការស៊ើបសួរ តាមអង្គហេតុដែលសហព្រះរាជអាជ្ញាប្តឹងមកខ្លួន ដោយធ្វើការវាយតម្លៃលើភស្តុតាងដាក់បន្ទុកទាំងឡាយ ដែលសហព្រះរាជអាជ្ញាបានបញ្ជូនមកភ្ជាប់ជាមួយនឹងសំណុំរឿង និងភស្តុតាងដោះបន្ទុកដែលខ្លួនទទួលបានបន្ថែមទៀត នៅក្នុងពេលដែលខ្លួនបានធ្វើការស៊ើបសួរ ព្រមទាំងភាពស៊ីសង្វាក់ដែលសង្ស័យថា បុគ្គលណាមួយបានប្រព្រឹត្តបទល្មើស។ ជាក់ស្តែង មាត្រា ៥៥ (២) នៃវិធានផ្ទៃក្នុង តម្រូវឱ្យសហចៅក្រមស៊ើបអង្កេត ត្រូវធ្វើការស៊ើបសួរតែអង្គហេតុណាដែលមានចែងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម។

៧. វិធាន ៥៥(៤) នៃវិធានផ្ទៃក្នុង ដែលចែងថា សហចៅក្រមស៊ើបអង្កេត *មានអំណាចបើកការស៊ើបសួរប្រឆាំងនឹងជនទាំងឡាយដែលមានឈ្មោះក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ*។ សហចៅក្រមស៊ើបអង្កេតអាចបើកកិច្ចស៊ើបសួរផងដែរ ចំពោះបុគ្គលគ្រប់រូបដែលមានតម្រុយច្បាស់លាស់ និងស៊ីសង្វាក់ បញ្ជាក់ថា បុគ្គលនោះអាចជាអ្នកទទួលខុសត្រូវក្នុងការប្រព្រឹត្តបទឧក្រិដ្ឋដែលមានចែងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ទោះបីជាបុគ្គលទាំងនោះមិនមានឈ្មោះក្នុងដីកាក៏ដោយ។ ក្នុងករណីចុងក្រោយនេះ សហចៅក្រមស៊ើបអង្កេតត្រូវសួរយោបល់សហព្រះរាជអាជ្ញា មុនពេលដាក់បុគ្គលនោះឱ្យស្ថិតនៅក្រោមការពិនិត្យ។

៨. ពាក្យថា "*មានអំណាចបើកការស៊ើបសួរ*" នៅក្នុងវិធាន **៥៥(៤)** នេះ បង្ហាញច្បាស់ថា វិធានបានផ្តល់ឆន្ទានុសិទ្ធិឱ្យសហចៅក្រមស៊ើបអង្កេត ក្នុងការសម្រេចដាក់អោយស្ថិតក្រោមការពិនិត្យរបស់ខ្លួននូវជនទាំងឡាយដែលមានឈ្មោះក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងមានអំណាចបើកការស៊ើបសួរផងដែរ ចំពោះជនផ្សេងទៀតដែលគ្មានឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។ បញ្ញត្តិនេះមិនបានចាប់បង្ខំឱ្យសហចៅក្រមស៊ើបអង្កេត ត្រូវតែដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យនូវបុគ្គលគ្រប់រូប ដែលមានឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់សហព្រះរាជអាជ្ញានោះទេ។ ម្យ៉ាងទៀត ***តាមមាត្រា ៥៥ (៥)*** ក៏គ្រាន់តែទុកសិទ្ធិឱ្យសហចៅក្រមស៊ើបអង្កេតសម្រេចថា តើគួរកោះហៅ ឬមិនកោះហៅ ជនសង្ស័យ ឬជនត្រូវចោទមកសួចម្លើយតែប៉ុណ្ណោះ។

៩. មានន័យថា នៅពេលដែលសហព្រះរាជអាជ្ញាបញ្ជូនដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដោយស្នើសុំដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ ឬ ស្នើសុំឱ្យឃុំខ្លួនបណ្តោះអាសន្នលើឈ្មោះបុគ្គលណាមួយជាក់លាក់នោះ សហចៅក្រមស៊ើបអង្កេតមានឆន្ទានុសិទ្ធិក្នុងការសម្រេចដាក់ ឬ មិនដាក់បុគ្គលនោះឱ្យស្ថិតនៅក្រោមការពិនិត្យ ឬឃុំខ្លួនបណ្តោះអាសន្ន។ ដូច្នេះ ចំពោះឈ្មោះជនត្រូវចោទដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមនោះ សហចៅក្រមស៊ើបអង្កេតមិនជាប់កាតព្វកិច្ចធ្វើតាមអ្វីដែលសហព្រះរាជអាជ្ញាប្តឹងមកនោះទេ។ ដូច្នេះ ការដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យជាសិទ្ធិរបស់សហចៅក្រមស៊ើបអង្កេត។

១០. តាមវិធាន ៥៧ (១)៖ នៅពេលជនត្រូវចោទចូលបង្ហាញខ្លួន ចំពោះមុខសហចៅក្រមស៊ើបអង្កេតជាលើកដំបូង សហចៅក្រមស៊ើបអង្កេតត្រូវកត់ត្រាទុកនូវអត្តសញ្ញាណរបស់ជននោះ និងប្រាប់ជននោះអំពីបទចោទប្រកាន់ និងអំពីសិទ្ធិមានមេធាវី និងសិទ្ធិក្នុងការនៅស្ងៀមមិនឆ្លើយនឹងសំណួរ។ បញ្ញត្តិនេះគ្រាន់តែបញ្ញត្តិអំពីសិទ្ធិការពារខ្លួនរបស់ជនជាប់ចោទតែប៉ុណ្ណោះ (*សិទ្ធិទទួលដំណឹងពីបទចោទប្រកាន់ សិទ្ធិមានមេធាវី និងសិទ្ធិក្នុងការនៅស្ងៀមមិនឆ្លើយនឹងសំណួរ*) នៅពេលដែលខ្លួនត្រូវមកបង្ហាញខ្លួន នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត ទោះបីជាបង្ហាញខ្លួនដោយខ្លួនឯងតាមរយៈដីកាបង្គាប់ឱ្យចូលខ្លួន ឬដោយបង្ខំ តាមរយៈដីកាបង្គាប់ឱ្យចាប់ខ្លួនក៏ដោយ។ បញ្ញត្តិនេះមិនតម្រូវឱ្យសហចៅក្រមស៊ើបអង្កេតដាច់ខាតត្រូវតែធ្វើការបង្គាប់ឱ្យជនត្រូវចោទចូលមកបង្ហាញខ្លួន នៅពេលសហចៅក្រមស៊ើបអង្កេតបានទទួលដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរនោះទេ ពោលគឺមិនកំណត់ថា នៅពេលណាមួយជាក់លាក់នោះឡើយ។

១១. ការដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ គឺធ្វើឡើងប្រឆាំងចំពោះបុគ្គលណាម្នាក់នៅពេលដែលសហចៅក្រមស៊ើបអង្កេតមានតម្រុយច្បាស់លាស់ ហើយសុីសង្វាក់យ៉ាងខ្លាំងថា ជននោះបានចូលរួមប្រព្រឹត្តបទល្មើស ក្នុងឋានៈជាចារី ឬ ជាអ្នកសមគំនិត។

១២. ដូចដែលបានលើកក្នុងកថាខណ្ឌទី ៤ ខាងលើ នៅក្នុងអំឡុងពេលនៃកិច្ចស៊ើបសួររបស់ខ្លួន ក្នុងសំណុំរឿង ០០៣ ចាប់ពីពេលបើកការស៊ើបសួរ រហូតដល់ពេលជូនសំណើងពីការបិទការស៊ើបសួរ សហ

ចៅក្រមស៊ើបអង្កេតមិនទាន់បានដាក់ជនណាម្នាក់ឱ្យស្ថិតនៅក្រោមការពិនិត្យនោះទេ មានន័យថា ក្នុងអង្គហេតុដែលសហព្រះរាជអាជ្ញាបញ្ជូនមកសហចៅក្រមស៊ើបអង្កេត តាមរយៈដីកាសន្និដ្ឋានបញ្ជូនឱ្យស៊ើបសួរនោះ គ្មានជនសង្ស័យណាម្នាក់ដែលសហចៅក្រមស៊ើបអង្កេតរកឃើញថាមានតម្រុយជាក់លាក់ និងស៊ីសង្វាក់ថា បានចូលរួមក្នុងការប្រព្រឹត្តបទល្មើសដូចដែលបានចោទប្រកាន់នោះទេ។

១៣. យោងតាមការបកស្រាយខាងលើ យើងយល់ឃើញថា មកទល់នឹងពេលចេញដីកាដែលរងការប្ដឹងជំទាស់នឹងពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់អ្នកដាក់ពាក្យសុំ Robert Hamill ក្នុងសំណុំរឿង ០០៣ នេះ អង្គហេតុដែលបានប្ដឹងមកសហចៅក្រមស៊ើបអង្កេត តាមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរនោះ សហចៅក្រមស៊ើបអង្កេតមិនទាន់អាចកំណត់ឈ្មោះជនត្រូវចោទបាននៅឡើយ។

១៤. ម្យ៉ាងទៀត ការប្ដឹងសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីធ្វើឡើងក្នុងគោលបំណងឱ្យទទួលបាននូវការជួសជុលការខូចខាតដែលបណ្ដាលមកពីអំពើល្មើសដល់ភាគីរងគ្រោះ។ អំពើល្មើសនោះ ត្រូវកើតឡើងដោយផ្ទាល់ពីអំពើរបស់ជនល្មើស រួមមាន ចារី សហចារី ។ល។

១៥. យើងយល់ឃើញថា កាលបើពុំមានជនត្រូវចោទដែលត្រូវទទួលខុសត្រូវក្នុងការជួសជុលការខូចខាតបណ្ដាលមកពីអំពើល្មើសរបស់ខ្លួនលើជនរងគ្រោះទេនោះ ការបដិសេធពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ក្នុងដំណាក់កាលនេះ មិនធ្វើអោយប៉ះពាល់ដល់សិទ្ធិជនរងគ្រោះឡើយ[១០]។

ភ្នំពេញ ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១១

ចៅក្រម ប្រាក់ គឹមសាន ចៅក្រម ន័យ ថុល ចៅក្រម ហ្វូត ទុទ្ធី

[១០] វិធាន ២៣ ស្ទួនបួន នៃវិធានផ្ទៃក្នុង ។

00748578

០០៣/០៧-០៩-២០០៩-អវតក/កសចស (អមជ០២)

លេខ/No: D11/2/4/4

# មតិយោបល់របស់ចៅក្រម LAHUIS និង ចៅក្រម DOWNING

១. តាំងពីដំបូងមក យើងយល់ថា វាជាការសំខាន់ក្នុងការលើកឡើងត្រួសៗទៅលើបរិបទនៃការដាក់ពាក្យសុំ និងការសម្រេចទៅលើពាក្យសុំ ដែលជាមូលដ្ឋាននៃមតិយោបល់របស់យើងចំពោះបញ្ហានេះ ទោះបីម្ចាស់បណ្ដឹងឧទ្ធរណ៍ និងមេធាវីរបស់គាត់ពុំបានដឹងឱ្យបានទូលំទូលាយ ដោយសារតែពួកគាត់មិនទាន់បានសិទ្ធិពិនិត្យសំណុំរឿងក៏ដោយ។

## ១) ការសង្កេតបឋមទៅលើតម្លាភាព និងលក្ខណៈប្រតិបត្តិនៃកិច្ចដំណើរការនីតិវិធី

២. ជាការសង្កេតបឋម យើងសូមកត់សម្គាល់ថា វិធីសាស្ត្រ និងនីតិវិធីដែលសហចៅក្រមស៊ើបអង្កេតយកមកអនុវត្តនៅក្នុងកិច្ចស៊ើបសួរសម្រាប់សំណុំរឿង ០០៣ មានភាពខុសគ្នាគួរឱ្យកត់សម្គាល់ពីនឹងវិធីសាស្ត្រ និងនីតិវិធីដែលត្រូវបានយកមកអនុវត្តនៅក្នុងសំណុំរឿង ០០១ និង សំណុំរឿង ០០២ នៅ អ.វ.ត.ក ហើយយើងកត់សម្គាល់ដែរថា ពុំមានការពន្យល់ពីការប្រើប្រាស់វិធីសាស្ត្រ និងនីតិវិធីផ្សេងនេះទេ។ ទីមួយ វិធីសាស្ត្រដែលសហចៅក្រមស៊ើបអង្កេតយកមកប្រើក្នុងកិច្ចស៊ើបសួរនេះទាំងមូលពុំមានភាពច្បាស់លាស់ទេ។ ទោះបីកិច្ចស៊ើបសួរត្រូវបានបញ្ចប់ទៅហើយក្ដី តែព័ត៌មានដែលនាំឱ្យមានការយល់ដឹងទាក់ទិននឹងគោលបំណងនៃកិច្ចស៊ើបសួរនេះ ត្រូវបានផ្ដល់តិចតួចណាស់។ ជាងនេះទៀត ពុំមានការពន្យល់ឱ្យបានច្បាស់ ថាតើវិសាលភាពនៃកិច្ចស៊ើបសួរត្រូវបានកំហិតទៅតាមអ្វីដែលមានរៀបរាប់នៅដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទីពីរឬយ៉ាងណា ថាតើមានការបញ្ចូលនូវបញ្ហាជាក់លាក់ណាមួយឬទេ និង ថាតើសិទ្ធិរបស់ភាគីនានាក្នុងដំណើរការនីតិវិធីនេះត្រូវបានយកមកពិចារណាដោយរបៀបណានោះទេ និង ថាតើសិទ្ធិទាំងនោះត្រូវបានយកមកថ្លឹងថ្លែងទល់នឹងលក្ខណៈពិសេសនៃកិច្ចស៊ើបសួរនេះឬទេ។ ទីពីរ នីតិវិធីដែលសហចៅក្រមស៊ើបអង្កេតយកមកអនុវត្ត ជាពិសេសទាក់ទិននឹងដំណើរការ និងការដោះស្រាយចំពោះពាក្យសុំពីភាគី និងអ្នកដាក់ពាក្យសុំនានានៅក្នុងដំណើរការនីតិវិធី មានភាពខុសគ្នាជាច្រើនអង្លើពីអ្វីដែលធ្លាប់បានយកមកអនុវត្តនៅក្នុងសំណុំរឿង ០០១ និង ០០២ ដោយសហចៅក្រមស៊ើបអង្កេតពុំបានពន្យល់ ឬពុំបានផ្ដល់ការជូនដំណឹងណាមួយជាមុនដល់ភាគី និងអង្គជំនុំជម្រះដែលទទួលបណ្ដឹងឧទ្ធរណ៍នោះទេ។ ដោយឡែកយើងកត់សម្គាល់ឃើញថា នៅក្នុងដំណើរការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី

PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE E.C.C.C * C.E.T.C

ក្នុងសំណុំរឿងនេះ និងការដាក់ឯកសារដោយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី សហចៅក្រមស៊ើបអង្កេតពុំបានបំពេញការងារឲ្យស៊ីសង្វាក់គ្នាទេ។ ប្រសិនបើមានមែន ព័ត៌មាន និងការពន្យល់ដែលសហចៅក្រមស៊ើបអង្កេតបានផ្តល់ទៅភាគី ឬអ្នកដាក់ពាក្យសុំនៅក្នុងដំណើរការនីតិវិធីនេះ ក៏ពុំមានសនិទានភាពមួយដែលស៊ីសង្វាក់គ្នាដែរ។ ខាងក្រោមនេះយើងសូមលើកយកឧទាហរណ៍មួយចំនួន ដែលបង្ហាញពីលក្ខណៈមិនស៊ីសង្វាក់គ្នានេះ។ យើងយល់ថាព័ត៌មានដែលមានបង្ហាញជូនខាងក្រោមនេះអាចផ្សព្វផ្សាយជាសាធារណៈបាន ដោយមិនរំលោភគោលការណ៍នៃភាពសម្ងាត់នៃកិច្ចស៊ើបសួរទេ ដោយសារពុំមានព័ត៌មានណាមួយត្រូវបានបញ្ចេញឲ្យដឹងនូវខ្លឹមសារនៃកិច្ចស៊ើបសួរ ឬអត្តសញ្ញាណរបស់ជនសង្ស័យរូបណាម្នាក់ឡើយ។

**ក) ការជូនដំណឹងពីបទចោទទៅឲ្យបុគ្គលដែលមានបង្ហាញឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរទីពីរ**

៣. ចាប់តាំងពីពេលបើកកិច្ចស៊ើបសួររហូតដល់ពេលប្រកាសបញ្ចប់កិច្ចស៊ើបសួរវិញ និងរហូតមកដល់ពេលនេះ សហចៅក្រមស៊ើបអង្កេតពុំបានជូនដំណឹងជាផ្លូវការដល់បុគ្គលដែលមានឈ្មោះថាជាជនសង្ស័យនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ នូវបទចោទ ឬពុំបានផ្តល់ព័ត៌មានពីកិច្ចស៊ើបសួរដែលបានធ្វើនោះទេ។ វិធីសាស្ត្រនេះខុសពីអ្វីដែលធ្លាប់បានធ្វើនៅក្នុងសំណុំរឿង ០០១ និង សំណុំរឿង ០០២ ដែលបុគ្គលមានឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរទីមួយត្រូវបាននាំខ្លួនមកចំពោះមុខសហចៅក្រមស៊ើបអង្កេត ក្នុងរយៈពេលប៉ុន្មានខែក្រោយពេលដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបានដាក់រួច ដើម្បីផ្តល់ព័ត៌មានជាផ្លូវការពីបទចោទប្រឆាំងនឹងបុគ្គលនោះ តាមរយៈការបង្ហាញខ្លួនជាលើកដំបូង ដោយអនុលោមតាមវិធាន ៥៧ នៃវិធានផ្ទៃក្នុង។ ទោះបីជាសហចៅក្រមស៊ើបអង្កេតមានអំណាចឆន្ទានុសិទ្ធិជាក់លាក់ ក្នុងការចេញសេចក្តីសម្រេចដើម្បីជូនដំណឹងជាផ្លូវការពីបទចោទ ដល់បុគ្គលដែលមានឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរក៏ដោយ ក៏សហចៅក្រមស៊ើបអង្កេតពុំបានផ្តល់ការពន្យល់ណាមួយនៅក្នុងសំណុំរឿងនេះ ឬពុំបានផ្តល់ការពន្យល់តាមវិធីផ្សេងទៀតពីមូលហេតុដែលធ្វើឲ្យខ្លួនអនុវត្តការងារក្នុងសំណុំរឿង ០០៣ ខុសពីរឿងក្តីមុនៗ និងពីមូលហេតុដែលជនសង្ស័យមិនត្រូវបានគេជូនដំណឹង ពីស្ថានភាពរបស់ខ្លួននៅក្នុងកិច្ចស៊ើបសួរ

នោះដែរ។ ចំណុចនេះអាចត្រូវបានចាត់ទុកថាមានបញ្ហា ទៅតាមអ្វីដែលមានរៀបរាប់នៅក្នុងសំណើនានា ដែលបានស្នើឡើងដោយសហព្រះរាជអាជ្ញាអន្តរជាតិ ដែលសំណើទាំងនោះមិនទាន់ត្រូវបានសម្រេចនៅឡើយទេ និងក៏មិនមានផ្តល់នូវការពន្យល់ណាមួយចំពោះករណីនេះដែរ[១]។

**ខ) ព័ត៌មានដល់ជនរងគ្រោះ និង អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលមានសក្តានុពល**

៤. ផ្ទុយពីអ្វីដែលធ្លាប់បានអនុវត្តកន្លងមកនៅក្នុងសំណុំរឿង ០០២[២] ជនរងគ្រោះពុំបានទទួលព័ត៌មានណាមួយអំពីកិច្ចស៊ើបសួរនៅក្នុងសំណុំរឿង ០០៣ ទេ ហើយក៏ពុំបានដឹងពីសិទ្ធិរបស់ខ្លួនក្នុងការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ឬដាក់ពាក្យបណ្តឹងក្នុងរឿងក្តីនេះ មុនពេលសហចៅក្រមស៊ើបអង្កេតសម្រេចបញ្ចប់កិច្ចស៊ើបសួរនៅថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១១ នោះដែរ។ សហ

---

[១] ដោយឡែក សហព្រះរាជអាជ្ញាអន្តរជាតិបានស្នើជាពិសេសសុំ [redacted]។ ក្រៅពីសំណើដែលបានស្នើសុំកាលពីថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨ សំណើទាំងពីរពុំទាន់ត្រូវបានសម្រេចនៅឡើយទេ ហើយក៏ពុំទាន់មានផ្តល់នូវការពន្យល់ចំពោះសកម្មភាពការងារនោះទេ៖ [redacted]

[២] នៅក្នុងសំណុំរឿង ០០២ សហចៅក្រមស៊ើបអង្កេតបានចេញសេចក្តីប្រកាសព័ត៌មានមួយនៅថ្ងៃទី ៥ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ដោយបានបញ្ចេញឱ្យដឹងនូវវិសាលភាពនៃកិច្ចស៊ើបសួរ និងបានជូនដំណឹងដល់ជនរងគ្រោះពីសិទ្ធិរបស់ពួកគាត់ក្នុងការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿងនេះ រយៈពេលជាងពីរខែមុនបញ្ចប់កិច្ចស៊ើបសួរ (នៅថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០១០)។ សហចៅក្រមស៊ើបអង្កេតបានពន្យារពេលកំណត់ពីរដងសម្រាប់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងការដាក់ព័ត៌មានបន្ថែម ដើម្បីគាំទ្រពាក្យសុំរបស់ខ្លួន ដោយបានផ្តល់រយៈពេល ៥ ខែបន្ថែមទៀត (រហូតដល់ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១០)។ អង្គបុរេជំនុំជម្រះបានពិចារណាសម្រេចនៅក្នុងសំណុំរឿង ០០២ ថា ព័ត៌មានដែលបានផ្តល់ដល់ជនរងគ្រោះពុំទាន់គ្រប់គ្រាន់ទេ និងមិនបានទាន់ពេលវេលាដែរ ដែលធ្វើឱ្យប៉ះពាល់ដល់សិទ្ធិរបស់ជនរងគ្រោះ៖ សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេតលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១០, ឯកសារលេខ D404/2/4, កថាខណ្ឌ ៥១-៥៤។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

ចៅក្រមស៊ើបអង្កេតគ្រាន់តែប្រកាសជាសាធារណៈនៅថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១១ ថា ខ្លួនបានបញ្ចប់កិច្ចស៊ើបសួរហើយ ដោយមិនបានផ្តល់ព័ត៌មានស្តីពីវិសាលភាពនៃកិច្ចស៊ើបសួរ ឬព័ត៌មានដទៃទៀតទាល់តែសោះ។ ព័ត៌មានតែមួយគត់ដែលបានប្រកាសជាសាធារណៈអំពីវិសាលភាពនៃកិច្ចស៊ើបសួរក្នុងសំណុំរឿង ០០៣ នោះគឺព័ត៌មានដែលសហព្រះរាជអាជ្ញាអន្តរជាតិបានផ្តល់ជូនតាមរយៈសេចក្តីប្រកាសព័ត៌មាននៅថ្ងៃទី ៩ ខែ ឧសភា ឆ្នាំ ២០១១[៣] ដែលត្រូវបានសម្រេចឱ្យដកចេញវិញតាមរយៈដីកាចេញដោយសហចៅក្រមស៊ើបអង្កេត[៤]។ ដោយអនុលោមតាមវិធានផ្ទៃក្នុង ជនរងគ្រោះមានរយៈពេល ១៥ ថ្ងៃ ក្នុងការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី បន្ទាប់ពីថ្ងៃបញ្ចប់កិច្ចស៊ើបសួរ ហេតុនេះជាគោលការណ៍ការដាក់ពាក្យត្រូវផុតកំណត់នៅថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១១[៥]។ ដូចដែលបានគូសបញ្ជាក់រួចមកហើយដោយអង្គបុរេជំនុំជម្រះ នៅក្នុង "សាលដីការបស់ខ្លួនទៅលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេតស្តីពីពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី" ក្នុងសំណុំរឿង ០០២ ដែលថា ការជូនដំណឹងគ្រប់គ្រាន់ និងទាន់ពេលវេលានូវវិសាលភាពនៃកិច្ចស៊ើបសួរ ជាប្រការសំខាន់សម្រាប់ឱ្យជនរងគ្រោះអនុវត្តនូវសិទ្ធិដែលខ្លួនទទួលបានតាមវិធាន ២៣*ស្ទួន* នៃវិធានផ្ទៃក្នុង[៦]។ ជាពិសេសសម្រាប់ជនរងគ្រោះដែលដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងរឿងក្តីណាមួយ ពួកគាត់ត្រូវបង្ហាញ *ដែលក្នុងចំណោមនោះ* ពីទំនាក់ទំនងរវាងព្យសនកម្មដែលបានទទួលរង និងយ៉ាងហោចណាស់ក៏មានឧក្រិដ្ឋកម្មមួយ ក្នុងចំណោមឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ប្រឆាំងជនត្រូវចោទណាម្នាក់។ ការបង្ហាញបែបនេះមិនអាចធ្វើឡើងបានទេ នៅពេលដែលពុំមានព័ត៌មានណាមួយត្រូវបានផ្តល់ឱ្យដឹងនោះ។ ដោយសារ ក្នុងសំណុំរឿង ០០២ ព័ត៌មានជាច្រើនត្រូវបានបង្ហាញឱ្យជន

---

[៣] សេចក្តីប្រកាសព័ត៌មានដែលមានចំណងជើងថា "សេចក្តីថ្លែងការណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិទាក់ទងនឹងសំណុំរឿងលេខ ០០៣" ចុះថ្ងៃទី ៩ ខែ ឧសភា ឆ្នាំ ២០១១។

[៤] ដីកាសម្រេចស្តីអំពីសេចក្តីប្រកាសព័ត៌មានជាសាធារណៈរបស់សហព្រះរាជអាជ្ញាអន្តរជាតិទាក់ទងនឹងសំណុំរឿង ០០៣ ចុះថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១១, ឯកសារលេខ D14។

[៥] វិធាន ២៣*ស្ទួន*(២) នៃវិធានផ្ទៃក្នុង។

[៦] សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេតលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១០, ឯកសារលេខ D404/2/4, កថាខណ្ឌ ៥១-៥៤។

PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C • C.E.T.C

រងគ្រោះបានដឹងតាំងពីដំណាក់កាលដំបូងៗនោះ អង្គបុរេជំនុំជម្រះយល់ឃើញថា សហចៅក្រមស៊ើបអង្កេតបានរំលោភសិទ្ធិរបស់ជនរងគ្រោះ ក្នុងការដែលខ្លួនមិនបានផ្តល់ព័ត៌មានឱ្យបានពេញលេញដល់ពួកគាត់។ ផ្ទុយពីការអនុវត្តកន្លងមកក្នុងសំណុំរឿង ០០២ និងក្រៅពីក្របខ័ណ្ឌជាក់លាក់ និងកំហិតដែលមានចែងក្នុងវិធានផ្ទៃក្នុង ជាពិសេសសិទ្ធិក្នុងការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងរឿងក្តីនានានៅ អ.វ.ត.ក សហចៅក្រមស៊ើបអង្កេតមិនបានផ្តល់ការពន្យល់ណាមួយទាល់តែសោះចំពោះការមិនបានផ្តល់ព័ត៌មានស្តីពីកិច្ចស៊ើបសួរដែលបានធ្វើនៅក្នុងសំណុំរឿង ០០៣ ដល់ជនរងគ្រោះ និងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលមានសក្តានុពលនោះ។

៥. យើងសូមកត់សម្គាល់ថា មិនមានអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីណាម្នាក់បានអនុវត្តសិទ្ធិរបស់ខ្លួនប្រកបដោយប្រសិទ្ធភាពក្នុងការចូលរួមក្នុងកិច្ចស៊ើបសួរ ដូចដែលមានចែងយ៉ាងច្បាស់ក្នុងវិធានផ្ទៃក្នុងទេ[៧] ហើយយើងក៏កត់សម្គាល់ផងដែរថា នៅក្នុងកម្រិតគួរឱ្យចាប់អារម្មណ៍ ស្ថានភាពនេះកើតឡើងដោយសារការមិនបានផ្តល់ព័ត៌មានជុំវិញកិច្ចស៊ើបសួរក្នុងសំណុំរឿង ០០៣។ ហេតុនេះ យើងយល់ថា សិទ្ធិរបស់ជនរងគ្រោះពុំត្រូវបានគេអើពើ និងត្រូវបានគេធ្វើឱ្យប៉ះពាល់យ៉ាងខ្លាំង។ យើងក៏សូមសង្កត់ធ្ងន់ផងដែរថា ការអនុញ្ញាតឱ្យចូលរួមក្នុងកិច្ចស៊ើបសួរតាមបញ្ញត្តិដែលមានចែងក្នុងវិធានផ្ទៃក្នុងតាមរយៈរូបភាពផ្សេងៗនោះ ទោះបីក្នុងនាមជាអ្នកដាក់ពាក្យបណ្តឹងក្តី[៨] ឬអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្តី ជនរងគ្រោះអាចនាំយកព័ត៌មានសំខាន់ៗ ពាក់ព័ន្ធនឹងអង្គហេតុដែលស្ថិតក្រោមកិច្ចស៊ើបសួរបាន រួមទាំងតួនាទីរបស់ជនសង្ស័យក្នុងឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់នោះផងដែរ។ ការបដិសេធមិនឱ្យជនរងគ្រោះបានចូលរួមក្នុងកិច្ចស៊ើបសួរ អាចធ្វើឱ្យសហចៅក្រមស៊ើបអង្កេតបាត់បង់នូវព័ត៌មានសំខាន់ៗក្នុងការ

---

[៧] សូមមើល *ក្នុងចំណោមនោះ* សិទ្ធិដែលផ្តល់ដល់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងកិច្ចស៊ើបសួរតាមវិធានផ្ទៃក្នុង វិធាន ៥៥(៨) (ការចុះទៅដល់ទីកន្លែងដោយសហចៅក្រមស៊ើបអង្កេត), វិធាន ៥៥(១០) (សំណើសុំបំពេញកិច្ចស៊ើបសួរ), វិធាន ៥៨(៥) (ចូលរួមក្នុងការតទល់គ្នា) វិធាន ៥៩(៥) (ស្នើសុំសហចៅក្រមស៊ើបអង្កេតស្តាប់ចម្លើយខ្លួន ស្តាប់ចម្លើយសាក្សី ចុះទៅដល់ទីកន្លែងកើតហេតុ បង្គាប់ឱ្យធ្វើកោសល្យវិច័យ ឬ ប្រមូលយកភស្តុតាងដទៃទៀត), វិធាន ៧៤(៤) (ធ្វើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេត) និង វិធាន ៧៦(២) (ស្នើសុំធ្វើមោឃភាពផ្នែកណាមួយនៃកិច្ចដំណើរការនីតិវិធី)។

[៨] វិធាន ៤៩(២) នៃវិធានផ្ទៃក្នុង អនុញ្ញាតឱ្យអ្នកដាក់ពាក្យបណ្តឹងអាចនាំព័ត៌មានទៅឱ្យសហព្រះរាជអាជ្ញាបាន។

ស្វែងរកការពិត ដែលនាំឱ្យកិច្ចស៊ើបសួរនោះមិនបានពេញលេញ និងលេចឡើងនូវការសង្ស័យពីភាពមិនលម្អៀងនៃកិច្ចស៊ើបសួរនេះ។

**គ) សិទ្ធិពិនិត្យសំណុំរឿងរបស់មេធាវីតំណាងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី**

៦. ផ្ទុយពីការអនុវត្តនៅក្នុងសំណុំរឿង ០០១ និងសំណុំរឿង ០០២ មេធាវីតំណាងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង ០០៣ ពុំបានទទួលសិទ្ធិពិនិត្យសំណុំរឿងឡើយ ទោះបីជាក្រោយពីបានដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងលិខិតតំណាងដោយអាណត្តិហើយក៏ដោយ។ ជាការពិត សំណើសុំសិទ្ធិពិនិត្យសំណុំរឿងរបស់មេធាវី ដែលបានដាក់សាជាថ្មី នៅតែពុំទទួលបានចម្លើយតប នៅពេលដែលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់កូនក្តីពួកគាត់ ត្រូវបានបដិសេធចោល និងសូម្បីមកទល់ពេលនេះហើយក្តី[៦]។ អាស្រ័យហេតុនេះ មេធាវីតំណាងម្ចាស់បណ្តឹងឧទ្ធរណ៍ ដែលបានដាក់បណ្តឹងឧទ្ធរណ៍ដោយពុំមានសិទ្ធិពិនិត្យសំណុំរឿង បានដាក់សំណើរបស់ខ្លួនទៅអង្គបុរេជំនុំជម្រះដើម្បីសុំសិទ្ធិពិនិត្យសំណុំរឿង។ តាមការយល់ឃើញរបស់យើង វិធាន ២៣ *ស្ទួន* (២) នៃវិធានផ្ទៃក្នុង នៅពេលពិចារណារួមជាមួយនឹងវិធាន ៥៥(៦) និង(១១) នៃវិធានផ្ទៃក្នុង បានផ្តល់លទ្ធភាពឱ្យអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិពិនិត្យសំណុំរឿង តាមរយៈមេធាវីតំណាងរបស់ខ្លួន គិតចាប់ពីពេលដាក់ពាក្យសុំរហូតដល់ពេលសេចក្តីសម្រេចបដិសេធចោលពាក្យសុំនេះ ចូលជាស្ថាពរ។ ដោយហេតុថា នៅក្នុងដំណាក់កាលនេះ ពុំមានហេតុផល ឬ ការពន្យល់ណាមួយ ពីសហចៅក្រមស៊ើបអង្កេត ចំពោះការដែលមិនផ្តល់សិទ្ធិឱ្យមេធាវីតំណាងម្ចាស់បណ្តឹងឧទ្ធរណ៍ ពិនិត្យសំណុំរឿង និងដោយហេតុថា វាមានសារៈសំខាន់ចំពោះមេធាវី ក្នុងការពិនិត្យសំណុំរឿង ដើម្បីអាចឱ្យពួកគាត់ដាក់បណ្តឹងឧទ្ធរណ៍បាន យើងគាំទ្រទៅតាមសំណើសុំសិទ្ធិពិនិត្យសំណុំរឿងនេះ ហេតុដូច្នេះ មេធាវីទទួលការអនុញ្ញាតឱ្យដាក់សារណាបណ្តឹងឧទ្ធរណ៍ បន្ថែមបាន ក្រោយពីខ្លួនមានសិទ្ធិពិនិត្យសំណុំរឿង។ ទោះបីជា

[៦] *សូមមើល៖* បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៦។ បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចស្តីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ សេង ចាន់ធារី ចុះថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១១ ឯកសារលេខ D11/1/4/1។ បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចស្តីពីភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ឈ្មោះ [redacted] ចុះថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១១ ឯកសារលេខ D11/4/1 (“បណ្តឹងឧទ្ធរណ៍ D11/4/1”)។

យ៉ាងនេះក្តី ដោយពិចារណាឃើញថា អង្គបុរេជំនុំជម្រះពុំអាចរកសំឡេងចំនួន បួន(៤) សំឡេងបានសេចក្តីសម្រេចលើសំណើសុំនេះពុំអាចរកបានឡើយ។

## ឃ) ការជូនដំណឹងអំពីឯកសារ ទៅមេធាវី និង អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី

៧. ទោះបីជាបានដាក់លិខិតតំណាងដោយអាណត្តិរួចហើយក្តី មេធាវីតំណាងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ពុំដែលទទួលបានការជូនដំណឹងអំពីឯកសារទាំងឡាយ ដែលបានដាក់នៅក្នុងសំណុំរឿង ០០៣ ជាច្រើនលើកច្រើនសា រួមទាំងឯកសារទាំងឡាយ ដែលពាក់ព័ន្ធនឹងពាក្យសុំរបស់កូនក្តីខ្លួនផងដែរ។ ឧទាហរណ៍ ក្រោយពីមេធាវីជាតិ និងអន្តរជាតិតំណាងម្ចាស់បណ្តឹងឧទ្ធរណ៍នេះ បានដាក់លិខិតតំណាងដោយអាណត្តិនៅថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០១១ ដែលលិខិតនេះបានផ្តល់សិទ្ធិអំណាចជាក់លាក់ដល់សហមេធាវី ក្នុងការទទួលបានការជូនដំណឹងអំពីឯកសារ ជំនួសមុខឱ្យម្ចាស់បណ្តឹងឧទ្ធរណ៍ សហមេធាវីបែរជាទទួលបានការជូនដំណឹងថា "ពួកគាត់ពុំទាន់បានទទួលស្គាល់ដោយសហចៅក្រមស៊ើបអង្កេតនៅឡើយទេ" នៅពេលសហមេធាវីបានដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍នេះ នៅថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១១[១០]។ ស្ថានភាពនេះនៅតែពុំមានការផ្លាស់ប្តូរ ទោះបីជាមកដល់ដំណាក់កាលនៃកិច្ចដំណើរការនីតិវិធីត្រឹមនេះហើយក៏ដោយ។ ជាលទ្ធផល មន្ត្រីទទួលបន្ទុកកិច្ចការសំណុំរឿងពុំទទួលបានសេចក្តីបង្គាប់ណាមួយ ឱ្យជូនដំណឹងដល់មេធាវីតំណាងម្ចាស់បណ្តឹងឧទ្ធរណ៍ អំពីឯកសារពាក់ព័ន្ធនឹងបណ្តឹងឧទ្ធរណ៍ ដែលពួកគាត់បានដាក់ ជំនួសមុខឱ្យម្ចាស់បណ្តឹងឧទ្ធរណ៍ឡើយ[១១]។ ចំណាត់ការបែបនេះ គឺផ្ទុយនឹងចំណាត់ការរួម ដែលបានធ្វើឡើងនៅក្នុងសំណុំរឿង ០០២ ពោលគឺ នៅពេលនោះ សេចក្តីសម្រេចទទួលស្គាល់មេធាវីតំណាងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី បានធ្វើឡើង ក្រោយពីពេលដាក់លិខិតតំណាងដោយអាណត្តិ មុនពេលធ្វើចំណាត់ការណាមួយផ្សេងចំពោះអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ហើយឯកសារទាំងអស់ដែលបានដាក់ជាបន្តបន្ទាប់ ត្រូវបាន

---

[១០] បញ្ជីចុះបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០១១។

[១១] ស្ថានភាពស្រដៀងគ្នា បានកើតឡើងនៅក្នុងបណ្តឹងឧទ្ធរណ៍មួយទៀត ដែលបានដាក់ដោយមេធាវី Silke Studzinsky និង ហុង គឹមសួន ជំនួសឱ្យអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលមានអត្តសញ្ញាណសម្ងាត់៖ បណ្តឹងឧទ្ធរណ៍ ឯកសារលេខ D11/4/1 កថាខណ្ឌ ៤។

ជូនដំណឹងដល់មេធាវី ស្របតាមវិធាន ៤៦(១) និងវិធាន ២៣ *ស្ទួនពីរ* (២) នៃវិធានផ្ទៃក្នុង ក៏ដូចជាទម្លាប់អនុវត្តរបស់កម្ពុជា និងអន្តរជាតិផងដែរ។ វានៅតែពុំទាន់មានការពន្យល់ថាតើហេតុអ្វីបានជាសហចៅក្រមស៊ើបអង្កេតយល់ឃើញថា មេធាវីតំណាងម្ចាស់បណ្តឹងឧទ្ធរណ៍ ចាំបាច់ទទួលស្គាល់ដោយសហចៅក្រមស៊ើបអង្កេតបន្ថែមទៀត ជាពិសេស នៅពេលដែលមេធាវីជាតិកម្ពុជាបានទទួលសិទ្ធិ*តាមផ្លូវច្បាប់*[១២] ឱ្យតំណាងកូនក្តីរបស់ពួកគាត់ ចំពោះមុខ អ.វ.ត.ក ភ្លាមៗរួចទៅហើយ ក្រោយពីបានដាក់លិខិតតំណាងដោយអាណត្តិ និងនៅពេលដែលមេធាវីអន្តរជាតិបានទទួលនីតិសម្បទា ទទួលស្គាល់ជាសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង ០០២ "និងតំណាងដើមបណ្តឹងរដ្ឋប្បវេណីផ្សេងទៀត ដែលអាចចាត់តាំង [មេធាវីរូបនេះ] នាពេលអនាគត ក្នុងគោលបំណងនៃកិច្ចស៊ើបសួរនៅចំពោះមុខ អ.វ.ត.ក រួចទៅហើយនោះ"[១៣]។ យើងយល់ឃើញថា សេចក្តីសម្រេចនេះ មានលក្ខណៈទូលំទូលាយ ហើយនៅពេលពិចារណារួមជាមួយនឹងវិធាន ២២(២)(ក) នៃវិធានផ្ទៃក្នុងដែលចែងថា នៅពេលទទួលស្គាល់រួចហើយ មេធាវីបរទេស "ត្រូវទទួលបានសិទ្ធិ និងបុព្វសិទ្ធិជាមេធាវីជាតិនៅចំពោះមុខ អ.វ.ត.ក"។ ទោះក្នុងករណីណាក៏ដោយ ប្រសិនបើសហចៅក្រមស៊ើបអង្កេតយល់ឃើញថា ការទទួលស្គាល់ចាំបាច់ត្រូវធ្វើឡើងចំពោះមេធាវីទាំងនេះ សេចក្តីសម្រេចបែបនេះ ត្រូវតែធ្វើឡើង មុនពេលសម្រេចលើពាក្យសុំដែលបានដាក់ជំនួសឱ្យកូនក្តីរបស់ពួកគាត់ ដើម្បីកុំឱ្យអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីបាត់បង់នូវលទ្ធភាព ក្នុងការទទួលបានការជួយជ្រោមជ្រែងពីមេធាវី ដូចមានចែងនៅក្នុងវិធានផ្ទៃក្នុង។ យើងយល់ឃើញថា យោងតាមចំណាត់ការដែលបានធ្វើឡើងនេះ សហចៅក្រមស៊ើបអង្កេត បានដកហូតសិទ្ធិមូលដ្ឋានរបស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី មួយចំនួនរួមទាំងម្ចាស់បណ្តឹងឧទ្ធរណ៍នេះផង ក្នុងការទទួលបានសិទ្ធិមានមេធាវីតំណាង។

៨. លើសពីនេះ យើងកត់សម្គាល់ឃើញថា ការជូនដំណឹងអំពីឯកសារ ដោយផ្ទាល់ទៅអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី តាមមធ្យោបាយជាឯកសារក្រដាស ដូចបានធ្វើឡើងជាទូទៅនៅក្នុងសំណុំរឿង ០០៣ នេះ ពុំបានធានាជាភស្តុតាងគ្រប់គ្រាន់បង្ហាញអំពីការជូនដំណឹងនេះឡើយ

[១២] សិទ្ធិមួយនេះកើតចេញពីអានុភាពនៃច្បាប់។

[១៣] ឯកសារលេខ D22/171/4។

ដោយហេតុថា យើងពុំអាចបញ្ជាក់ថាតើឯកសារមួយចំនួន ពិតជាបានទទួលដោយបុគ្គលដែលយើងចង់ផ្ញើទៅនោះដែរឬក៏អត់។ វិធានផ្ទៃក្នុង និងសេចក្តីណែនាំអនុវត្តស្តីអំពីការដាក់ឯកសារចំពោះមុខ អ.វ.ត.ក បង្គាប់ថា ក្រឡាបញ្ជី និង/ឬមន្ត្រីទទួលបន្ទុកកិច្ចការសំណុំរឿងត្រូវ i) កត់ត្រានៅក្នុងរបាយការណ៍ជាលាយលក្ខណ៍អក្សរ ដោយបញ្ជាក់អំពីមធ្យោបាយ ដែលបានប្រើក្នុងការជូនដំណឹងនេះ ពេលវេលា ថ្ងៃខែឆ្នាំ ទីកន្លែង និងកាលៈទេសៈដទៃទៀត[១៤] ii) ខិតខំឱ្យអស់ពីលទ្ធភាព ដើម្បីប្រគល់ដីកា និងទទួលបានមកវិញនូវសេចក្តីបញ្ជាក់ទទួលស្គាល់ថាបានទទួលដីកា ដែលត្រូវដាក់ភ្ជាប់ទៅនឹងរបាយការណ៍នៃការបំពេញកិច្ចការ[១៥] និង iii) បំពេញទម្រង់បែបបទស្តីអំពី "ការទទួលស្គាល់នៃការជូនដំណឹង"[១៦] ដែលមន្ត្រីទទួលបន្ទុកកិច្ចការសំណុំរឿង ឬ មន្ត្រីដែលបានចាត់តាំងដោយផ្នែកគ្រប់គ្រងតុលាការ ត្រូវបញ្ជាក់អំពីការជូនដំណឹងអំពីឯកសារ[១៧]។ ឯកសារមួយចំនួននៅក្នុងសំណុំរឿង ០០៣ ត្រូវបានបញ្ជូនជាការជូនដំណឹងតាមរយៈក្រុមហ៊ុន TNT ឬ អ្នករត់សំបុត្រផ្សេងទៀត ដោយមិនបានធ្វើរបាយការណ៍ឱ្យបានច្បាស់លាស់ ដែលបង្ហាញថាតើឯកសារណាមួយឬឯកសារទាំងឡាយណាដែលត្រូវបានបញ្ជូន ឬអ្នកណាជាអ្នកទទួលឯកសារ ដោយគ្មានការបញ្ជាក់ពីអ្នកដែលត្រូវទទួលឯកសារ និងថែមទាំងដោយគ្មានការបញ្ជាក់ណាមួយពីមន្ត្រីទទួលបន្ទុកកិច្ចការសំណុំរឿង ឬមន្ត្រីដែលបានចាត់តាំងដោយផ្នែកគ្រប់គ្រងតុលាការថា ឯកសារនេះពិតជាបានបញ្ជូនទៅដល់អ្នកទទួលពិតប្រាកដមែន[១៨]។ ទម្រង់បែបបទស្តីអំពី "ការបញ្ជាក់ថាបានទទួលការជូនដំណឹង" មួយចំនួន ដែលបានបំពេញនៅក្នុងសំណុំរឿង ០០៣ គ្រាន់តែបានបញ្ជាក់ថា ឯកសារនេះបានទទួលដោយមន្ត្រីទទួលបន្ទុកកិច្ចការសំណុំរឿង ដែលមានភារៈជូនដំណឹងតែប៉ុណ្ណោះ។ ការ ជូនដំណឹងអំពីដីកាកែប្រែ ដែលនឹងយកមកពិភាក្សាឱ្យបានលម្អិតនៅខាងក្រោម គឺជាឧទាហរណ៍មួយនៃទម្លាប់ជូនដំណឹង ដែលបានអនុវត្តនៅក្នុងសំណុំរឿង ០០៣ ហើយបានបង្ហាញអំពីផលវិបាក ជាលក្ខណៈអវិជ្ជមានចំពោះភាគី នៅពេលដែលមានការអនុវត្តពុំបានត្រឹមត្រូវ ទៅតាមនីតិវិធីនៃ

[១៤] វិធាន ៤៦(២)នៃវិធានផ្ទៃក្នុង។

[១៥] វិធាន ៤៦(៣)នៃវិធានផ្ទៃក្នុង។

[១៦] មាត្រា ១១.២ នៃសេចក្តីណែនាំអនុវត្តស្តីអំពីការដាក់ឯកសារនៅចំពោះមុខ អ.វ.ត.ក។

[១៧] ឧបសម្ព័ន្ធ ង នៃសេចក្តីណែនាំអនុវត្តស្តីអំពីការដាក់ឯកសារនៅចំពោះមុខ អ.វ.ត.ក។

[១៨] សូមមើល ការជូនដំណឹងអំពីដីកាដែលត្រូវបានជំទាស់ និងដីកាកែប្រែ ដល់ម្ចាស់បណ្តឹងឧទ្ធរណ៍ និងការជូនដំណឹងនៃដីកាសម្រេចស្តីពីភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] D11/3។

ការជូនដំណឹង។

**ង) ការពន្យារពេលនៅក្នុងការចុះបញ្ជីនូវឯកសារដែលបានដាក់**

៩. ទោះបីវាជាការអនុវត្តនៅក្នុងសំណុំរឿង ០០១ និងសំណុំរឿង ០០២ និងទោះបីជាគេរំពឹងគិតទុកថា ឯកសារទាំងឡាយ ដែលដាក់ជូនដោយភាគី ឬ អ្នកដាក់ពាក្យសុំនៅក្នុងកិច្ចដំណើរការនីតិវិធី នឹងត្រូវបានដាក់ ជូនដំណឹង និងបញ្ចូលទៅក្នុងសំណុំរឿង ក្រោយពីក្រឡាបញ្ជីនៃការិយាល័យសហចៅក្រមស៊ើបអង្កេតបានទទួលពីមន្ត្រីទទួលបន្ទុកកិច្ចការសំណុំរឿងក៏ដោយ[១៩] ក៏ការពន្យារពេលយ៉ាងយូរ ដោយគ្មានហេតុផល ចំពោះការចាត់ចែងលើឯកសារ និងចំពោះការដាក់ឯកសារទាំងនេះទៅក្នុងសំណុំរឿង ត្រូវបានកត់សម្គាល់ឃើញកើតមានឡើងនៅក្នុងសំណុំរឿង ០០៣។ កាលបរិច្ឆេទនៃការដាក់ឯកសារ ត្រូវបានចុះនៅក្នុងប្រព័ន្ធ Zylab ដែលជាប្រព័ន្ធអេឡិចត្រូនិករបស់តុលាការ ដោយគ្រាន់តែធ្វើការយោងទៅរកកាលបរិច្ឆេទ ដែលភាគីបានដាក់ឯកសារ ពោលគឺមិនបានចង្អុលបញ្ជាក់ឱ្យបានជាក់លាក់អំពីកាលបរិច្ឆេទ ដែលឯកសារទាំងនេះបានជូនដំណឹង និងបញ្ចូលទៅក្នុងសំណុំរឿងឡើយ។ ឧទាហរណ៍ ទោះបីជាពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍បានទទួលដោយមន្ត្រីទទួលបន្ទុកកិច្ចការសំណុំរឿងនៅថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០១១ ហើយបានចុះនៅក្នុងប្រព័ន្ធ Zylab ថាបានដាក់នៅក្នុងថ្ងៃនេះក៏ដោយ ក៏ពាក្យសុំនេះ ទើបតែបានដាក់បញ្ចូលទៅក្នុងសំណុំរឿងនៅថ្ងៃទី ២៩ ខែ មេសា នៅវេលាម៉ោង ១៤:៤០ នាទី[២០] ពោលគឺតែ ៣០ នាទី ប៉ុណ្ណោះ មុនពេលដាក់ដីកាសម្រេចដែលត្រូវបានជំទាស់ ដូចបានបង្ហាញឱ្យឃើញតាមរយៈសេចក្តីណែនាំស្តីពីការដាក់ឯកសារ ដែលមិនមែនជាផ្នែកមួយនៃសំណុំរឿងនោះទេ ក៏ប៉ុន្តែ សេចក្តីណែនាំស្តីពីការដាក់ឯកសារនេះ រក្សាទុកដោយមន្ត្រីទទួលបន្ទុកកិច្ចការសំណុំរឿង[២១]។ ឯកសារជាច្រើននៅក្នុងសំណុំរឿងនេះរបស់សហព្រះរាជអាជ្ញាអន្តរជាតិ

---

[១៩] មាត្រា ២.១ និងមាត្រា ២.៤ នៃសេចក្តីណែនាំអនុវត្តស្តីអំពីការដាក់ឯកសារនៅចំពោះមុខ អ.វ.ត.ក។

[២០] ទម្រង់បែបបទណែនាំស្តីពីការដាក់ឯកសារ ដែលបំពេញដោយក្រឡាបញ្ជីនៃការិយាល័យសហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១១។ ទម្រង់បែបបទនេះ មិនមានដាក់នៅក្នុងសំណុំរឿងនោះទេ ប៉ុន្តែសហចៅក្រមអន្តរជាតិទទួលបាន ពីមន្ត្រីទទួលបន្ទុកកិច្ចការសំណុំរឿង ក្រោយពីបានដាក់សំណើ។

[២១] ករណីដូចគ្នានេះ បានកើតឡើងនៅក្នុងករណី សេង ធារី ដែលបានដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង ០០៣ ផងដែរ។ នៅក្នុងករណីអ្នកដាក់ពាក្យសុំទី ៣ ដែលមកត្រឹមដំណាក់កាលនេះ លេខអត្តសញ្ញាណសម្ងាត់ ពាក្យ

ក៏ត្រូវបានដាក់ដោយមានការយឺតយ៉ាវយ៉ាងខ្លាំង ហើយសហចៅក្រមស៊ើបអង្កេតក៏មានការយឺតយ៉ាវនៅក្នុង ការដាក់ឯកសាររបស់ខ្លួនដែលរួមមាន ដីកាចាត់ឲ្យស៊ើបសួរជំនួស របាយការណ៍ស្តីពីការអនុវត្តដីកាចាត់ឲ្យស៊ើបសួរជំនួស និងកំណត់ហេតុនៃការស្តាប់ចម្លើយ[២២] យើងសូមគូសបញ្ជាក់ថា មន្ត្រីតុលាការមានកាតព្វកិច្ចចាំបាច់ត្រូវចាត់ចែងលើឯកសារឲ្យបានលឿន នៅពេលឯកសារទាំងនោះ បានដាក់មក ដើម្បីធ្វើយ៉ាងណាឲ្យសំណុំរឿងមានបច្ចុប្បន្នភាព[២៣] និងគោរពទៅតាមកាលបរិច្ឆេទផុតកំណត់។ ការពន្យារពេលនៅក្នុងការដាក់ឯកសារ អាចមានផលប៉ះពាល់ជាលក្ខណៈអវិជ្ជមានចំពោះការអនុវត្តសិទ្ធិទាំងឡាយ ដែលបានប្រគល់ជូនភាគី ឬ អ្នកដាក់ពាក្យសុំនៅក្នុងកិច្ចដំណើរការនីតិវិធី ដូចមានចែងនៅក្នុងវិធាននៃផ្ទៃក្នុង។ ករណីនេះហាក់ដូចជាបានកើតឡើងនៅក្នុងរឿងនេះ ពោលគឺ ការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ តែប៉ុន្មាននាទី មុនពេលសម្រេចបដិសេធពាក្យសុំនេះចោល ទំនងជាអាចចាត់ទុកថាជាការប៉ុនប៉ងរារាំងម្ចាស់ បណ្តឹងឧទ្ធរណ៍ មិនឲ្យអនុវត្តសិទ្ធិពិនិត្យសំណុំរឿង[២៤] និងចូលរួមនៅក្នុងកិច្ចស៊ើបសួរ។ យើងកត់សម្គាល់ឃើញទៀតថា មកត្រឹមពេលនេះ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលបានដាក់នៅក្នុងរឿងក្តីនេះ ក៏ជាបណ្តឹងផងដែរ ដូច្នេះ ពាក្យសុំទាំងនេះត្រូវបាន

---

សុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងឯកសារពាក់ព័ន្ធ ក៏បានដាក់មកដែរ ក្រោយពីពេលចេញដីកាសម្រេចបដិសេធពាក្យសុំនេះ។ នៅពេលអង្គបុរេជំនុំជម្រះ បានទទួលបណ្តឹងឧទ្ធរណ៍ ឯកសារទាំងនេះ នៅមិនទាន់មាននៅក្នុងសំណុំរឿងនៅឡើយទេ ក៏ប៉ុន្តែ បានដាក់ ក្រោយពីមានការស្នើសុំទៅក្រឡាបញ្ជីនៃការិយាល័យសហចៅក្រមស៊ើបអង្កេត ឲ្យធ្វើបច្ចុប្បន្នភាពលើសំណុំរឿងតែប៉ុណ្ណោះ។

[២២] មានការជូនដំណឹងអំពីការយឺតយ៉ាវរហូតដល់ ៧ សប្តាហ៍ក្នុងការដាក់ឯកសារជាច្រើនរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ហើយការដាក់ ដីកាចាត់ឲ្យស៊ើបសួរជំនួសលើកទីមួយនេះទៅក្នុងសំណុំរឿង មានការយឺតយ៉ាវជិតមួយឆ្នាំ។ ចំពោះព័ត៌មានលម្អិតបន្ថែម សូមមើល *ក្នុងចំណោមនោះ* តារាងនៃការយឺតយ៉ាវក្នុងការជូនដំណឹងរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតក្នុងការជូនដំណឹងរបស់សហចៅក្រមស៊ើបអង្កេតអំពីសេចក្តីសម្រេចសំខាន់ៗ និងសារណាទាក់ទងនឹងសំណុំរឿង ០០៣ ដាក់ជាឧបសម្ព័ន្ធ ១ នៃបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹង "ដីកាសម្រេចស្តីពីការដាក់ឯកសារជាថ្មីនូវសំណើសុំបំពេញកិច្ចស៊ើបសួរចំនួនបីរបស់សហព្រះរាជអាជ្ញាអន្តរជាតិនៅក្នុងសំណុំរឿង ០០៣" ថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០១១ លេខ D26/1/1.1.28។

[២៣] អនុលោមតាមវិធាន ៧៧ (២) និង (៣) នៃវិធានផ្ទៃក្នុង អង្គបុរេជំនុំជម្រះត្រូវទទួលបានសំណុំរឿង ដែលមានបច្ចុប្បន្នភាពនៅពេលទទួលបានបណ្តឹងឧទ្ធរណ៍។

[២៤] សូមមើលការពិភាក្សានៅក្នុងកថាខណ្ឌ ៥ ខាងលើ ស្តីពីសិទ្ធិពិនិត្យសំណុំរឿង។

បញ្ជូនបន្តជាបន្ទាន់ទៅឲ្យ សហព្រះរាជអាជ្ញា ដើម្បីចាត់ការទៅតាមវិធាន ៤៩(២) នៃវិធានផ្ទៃក្នុង។

១០. មកត្រឹមពេលនេះ យើងសូមគូសបញ្ជាក់ថា ទោះបីជាសហចៅក្រមស៊ើបអង្កេតមានឆន្ទានុសិទ្ធិមួយចំនួននៅក្នុងការដឹកនាំកិច្ចស៊ើបសួររបស់ខ្លួន ហើយអាចសម្របសម្រួលចំណាត់ការរបស់ខ្លួនទៅតាមភាពចាំបាច់នៃរឿងក្តីនេះក៏ពិតមែន ក៏ឆន្ទានុសិទ្ធិនេះត្រូវតែអនុវត្តនៅក្នុងក្របខ័ណ្ឌ ដូចមានចែងនៅក្នុងវិធានផ្ទៃក្នុង និងវិធានជាធរមានផ្សេងទៀត នៅចំពោះមុខ អ.វ.ត.ក។ ទោះបីជាទទួលស្គាល់នូវគោលការណ៍រក្សាការសម្ងាត់នៃកិច្ចសួរស៊ើបសួរក៏ដោយ[២៥] យើងសូមគូសបញ្ជាក់ថា ឆន្ទានុសិទ្ធិរបស់សហចៅក្រមស៊ើបអង្កេត ត្រូវតែអនុវត្តក្នុងលក្ខណៈមួយតម្លាភាពគ្រប់គ្រាន់ ដើម្បីអនុញ្ញាតឲ្យភាគីពាក់ព័ន្ធមានឱកាសអនុវត្តសិទ្ធិរបស់ខ្លួន នៅក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរ ព្រមទាំងដើម្បីឲ្យអង្គជំនុំជម្រះ ដែលមានភារៈទទួលខុសត្រូវចំពោះការពិនិត្យឡើងវិញលើដីកាសម្រេច និងសេចក្តីសម្រេច មានព័ត៌មានគ្រប់គ្រាន់សម្រាប់សម្រេចលើសិទ្ធិទាំងនេះ។ នៅក្នុងន័យនេះ យើងកត់សម្គាល់ឃើញថា សហចៅក្រមស៊ើបអង្កេតមានភារៈធានានូវសច្ចាភាពតាមផ្លូវច្បាប់ និងតម្លាភាពនៃកិច្ចដំណើរការនីតិវិធី ដោយអនុលោមតាមវិធាន ២១(១) នៃវិធានផ្ទៃក្នុង។ ការផ្តល់ព័ត៌មានគ្រប់គ្រាន់ និងការបញ្ជាក់បំភ្លឺឲ្យបានច្បាស់លាស់អំពីវិធីសាស្ត្រ និងនីតិវិធី ដែលខ្លួនអនុវត្តតាម ក៏មានភាពចាំបាច់ក្នុងការផ្តល់ឱកាសដល់ភាគីពាក់ព័ន្ធ បង្ហាញរឿងក្តីរបស់ខ្លួន និងមានឥទ្ធិពលលើសេចក្តីសម្រេចរបស់តុលាការ ដែលខ្លួនមានសិទ្ធិអាចធ្វើដូច្នេះ ដោយអនុលោមតាមក្នុងវិធានផ្ទៃក្នុង។ ការធ្វើដូច្នេះ វាជាការធានាថា កិច្ចដំណើរការនីតិវិធីមានភាពយុត្តិធម៌ និងគោរពគោលការណ៍ចំពោះមុខ[២៦] ដែលជាលក្ខខណ្ឌតម្រូវនៅក្នុងវិធាន ២១ នៃវិធានផ្ទៃក្នុង និងមាត្រា ១៤(១) នៃ កតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។ សហចៅក្រមស៊ើបអង្កេត មានភាពចាំបាច់

---

[២៥] វិធាន ៥៦ (១) នៃវិធានផ្ទៃក្នុង។

[២៦] សិទ្ធិទទួលបាននីតិវិធីចំពោះមុខ ដែលបានកំណត់ដោយតុលាការសិទ្ធិមនុស្សអឺរ៉ុប (“តុលាការសិទ្ធិមនុស្សអឺរ៉ុប”) មានន័យជាក់លាក់ជាងនេះ ដោយសំដៅលើ “លទ្ធភាពឲ្យភាគីនៃការជំនុំជម្រះលើករណីរដ្ឋប្បវេណី និងព្រហ្មទណ្ឌ បានដឹង និងផ្តល់យោបល់លើគ្រប់ភស្តុតាងទាំងអស់ ដែលបានបង្កើតឡើង ឬ លើគ្រប់សេចក្តីសង្កេតទាំងអស់ ដែលបានដាក់ក្នុងគោលបំណងផ្តល់ជាអានុភាពលើសេចក្តីសម្រេចរបស់តុលាការ”៖ រឿងក្តី *Ferreira Alves ទល់នឹង ប្រទេសព័រទុយហ្គាល់* ពាក្យសុំលេខ 25053/05 សាលក្រម ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០៧ កថាខណ្ឌ ៣៧។

ជាសារវ័ន្ត នៅក្នុងការធានាចំពោះការគោរពនីតិវិធី "ដែលបានបង្កើតឡើង ដើម្បីទទួលបាន 'ភាពយុត្តិធម៌ទៅតាមនីតិវិធី' មិនមែនដើម្បី 'ភាពយុត្តិធម៌ ទៅតាមលទ្ធផលដែលខ្លួនចង់បាននោះទេ'"[២៧]។ ដូចតុលាការសិទ្ធិមនុស្សអឺរ៉ុបបានលើកឡើង ការទទួលស្គាល់ដោយម្ចាស់បណ្តឹងថា ខ្លួនធ្លាប់មានឱកាសបង្ហាញនូវទស្សនៈរបស់ខ្លួន នៅមុនពេលចេញសេចក្តីសម្រេចដែលប៉ះពាល់សិទ្ធិរបស់ខ្លួន គឺជាមូលដ្ឋាននៃការជឿទុកចិត្តលើការងារស្វែងរកយុត្តិធម៌ ដែលវាជាការការពារផលប្រយោជន៍របស់ភាគី ក៏ដូចជា ផលប្រយោជន៍នៃការស្វែងរកយុត្តិធម៌ឱ្យបានត្រឹមត្រូវផងដែរ[២៨]។ យើងមិនអាចទទូចលើកឡើងអំពីភាពចាំបាច់ក្នុងការទាមទារឱ្យស្ថាប័នតុលាការ រួមមាន សហចៅក្រមស៊ើបអង្កេត គោរពឱ្យបានតឹងរ៉ឹងលើសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងសិទ្ធិនីតិវិធីរបស់បុគ្គល ពាក់ព័ន្ធនៅក្នុងកិច្ចដំណើរការនីតិវិធី ដែលសិទ្ធិទាំងនេះ នៅក្នុងសង្គមប្រជាធិបតេយ្យ[២៩] គឺជាការធានាជាមូលដ្ឋាននៃនីតិរដ្ឋ[៣០] ជាពិសេស នៅក្នុងបរិបទនៃសំណុំរឿង ០០៣។

១១. ដូចការពន្យល់បន្ថែមនៅក្នុងចំណុចខាងក្រោម ការដាក់ និងការជូនដំណឹងអំពីឯកសារ ដែលភាគីបានដាក់មកឱ្យបានត្រឹមត្រូវ ចំពោះអ្នកមានសិទ្ធិទទួលបានការជូនដំណឹង គឺជាវិធានការចាំបាច់ និងដំបូងគេបំផុត នៅក្នុងការធានាភាពយុត្តិធម៌នៃកិច្ចដំណើរការនីតិវិធី។

**ខ) ដីកាកែប្រែ**

១២. ដូចបានលើកឡើងដោយសង្ខេបនៅក្នុងប្រវត្តិនីតិវិធី សហចៅក្រមស៊ើបអង្កេតបានដាក់ដីកាកែប្រែ

---

[២៧] Stefan Trechsel *សិទ្ធិមនុស្សនៅក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ* Oxford University Press ("Trechsel") ទំព័រ ៨៣។

[២៨] រឿងក្តី *Niderost-Huber ទល់នឹង ប្រទេសស្វីស* សាលក្រម ចុះថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៧ កថាខណ្ឌ ២៩-៣០។ រឿងក្តី *Ferreira Alves ទល់នឹង ប្រទេស*ព័រទុយហ្គាល់ពាក្យសុំលេខ 25053/05 សាលក្រម ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០៧ កថាខណ្ឌ ៤១។ សូមមើលផងដែរនូវ Trechsel ទំព័រ ៨៩។

[២៩] សូមមើល *តុលាការសិទ្ធិមនុស្សអឺរ៉ុប* រឿងក្តី *AB ទល់នឹង ប្រទេសស្លូវ៉ាគី* ពាក្យសុំលេខ 41784/98 សាលក្រម ចុះថ្ងៃទី ៤ ខែ មីនា ឆ្នាំ ២០០៣ កថាខណ្ឌ ៥៤។

[៣០] *តុលាការសិទ្ធិមនុស្សអឺរ៉ុប* រឿងក្តី *Golder ទល់នឹង ចក្រភពអង់គ្លេស* ពាក្យសុំលេខ 4451/70 សាលក្រម ចុះថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ១៩៧៥ កថាខណ្ឌ ៣៤ ដែលបានលើកឡើងផងដែរនៅក្នុងរឿងក្តី *Z និងជនដទៃទៀត ទល់នឹង ចក្រភពអង់គ្លេស* 29392/95 សាលក្រម ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០០១ កថាខណ្ឌ ៩១។

ជាភាសាអង់គ្លេស នៅថ្ងៃទី ៧ ខែ កក្កដា ឆ្នាំ ២០១១ និងបន្ទាប់មកដីកាកែប្រែជាភាសាខ្មែរត្រូវបាន ដាក់នៅថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០១១ ដោយដីកាដែលត្រូវបានជំទាស់នេះ មានការកែប្រែ ដូចខាងក្រោម៖

- នៅក្នុងផ្នែកសេចក្តីសម្រេចចុងក្រោយ ទោះបីជាដីកាដែលត្រូវបានជំទាស់នេះ បានបដិសេធ ពាក្យសុំលេខ D5/2 របស់ដើមបណ្តឹងឧទ្ធរណ៍ ដែលបានសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងសំណុំរឿង ០០៤ ក្តី ក៏ប៉ុន្តែ ដីកាកែប្រែបែរជាបដិសេធពាក្យសុំលេខ D11/2 នៅក្នុង សំណុំរឿង ០០៣ ទៅវិញ។
- ទោះបីជាដីកាដែលត្រូវបានជំទាស់ បានយោងលើលេខសំណុំរឿង ០០៤ នៅក្នុងក្បាលទំព័រក្តី ក៏ប៉ុន្តែ ដីកាកែប្រែបែរជាមានលេខសំណុំរឿង ០០៣ ទៅវិញ។
- ទោះបីជាដីកាដែលត្រូវបានជំទាស់ បានយោងលើសេចក្តីពិចារណានៃដីកាសន្និដ្ឋានបញ្ជូនរឿង ឱ្យស៊ើបសួរទី ៣ មុនពេលសម្រេចក៏ដោយ ក៏ប៉ុន្តែ ដីកាកែប្រែ បែរជាយោងលើសេចក្តី ពិចារណានៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទីពីរ ទៅវិញ។
- ប្រអប់សម្រាប់ចុះហត្ថលេខានៃដីកាដែលត្រូវបានជំទាស់ មានលក្ខណៈខុសពីប្រអប់សម្រាប់ ចុះហត្ថលេខានៅក្នុងដីកាកែប្រែ។

១៣. ដីកាដែលត្រូវបានជំទាស់ បានដកចេញពីក្នុងសំណុំរឿង ហើយជំនួសដោយដីកាកែប្រែ។ ទោះបីជា ដីកាកែប្រែទំនងជាបានធ្វើឡើងនៅថ្ងៃទី ៦ ខែ កក្កដា ឆ្នាំ ២០១១ ក៏ដោយ ដីកាកែប្រែនេះបែរជា ដាក់កាលបរិច្ឆេទត្រឡប់ថយក្រោយវិញ ពោលគឺ ថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១១។ យើងសង្កេត ឃើញទៀតថា សេចក្តីណែនាំស្តីពីការដាក់ឯកសារ ក៏បានដាក់កាលបរិច្ឆេទត្រឡប់ថយក្រោយ ទៅថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១១ ដូចគ្នា ទោះបីជាដីកាកែប្រែ ត្រូវបានកត់សម្គាល់យ៉ាងជាក់លាក់ ដោយមន្ត្រីទទួលបន្ទុកសំណុំរឿងថា ដីកាកែប្រែនេះ ពិតជាបានដាក់នៅថ្ងៃទី ៧ ខែ កក្កដា ឆ្នាំ ២០១១ ក៏ដោយ។ ដីកាកែប្រែនេះ ពុំបានជូនដំណឹងដល់ភាគី និងអង្គបុរេជំនុំជម្រះឡើយ បើទោះជា សេចក្តីជូនដំណឹងអំពីការប្តឹងឧទ្ធរណ៍ បានចុះបញ្ជី និងជូនដំណឹងនៅថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១១ ក៏ដោយ។ ជាពិសេស យើងកត់សម្គាល់ពុំឃើញមានការចេញសេចក្តីបង្គាប់ណាមួយ

00748592



ឲ្យធ្វើការជូនដំណឹងដល់មេធាវីតំណាងម្ចាស់បណ្តឹងឧទ្ធរណ៍នេះឡើយ[៣១] ហើយ យើងកត់សម្គាល់ ពុំឃើញមានភស្តុតាងគ្រប់គ្រាន់ឲ្យយើងសន្និដ្ឋានថា ដីកាកែប្រែនេះពិតជាបានជូនដំណឹងដល់ម្ចាស់ បណ្តឹងឧទ្ធរណ៍មែន[៣២]។ ចំណុចនេះក៏ដូចគ្នាផងដែរចំពោះការបកប្រែជាភាសាខ្មែរ ដែលបានដាក់

---

[៣១] សូមមើល សេចក្តីណែនាំស្តីពីការដាក់ឯកសារ និងការជូនដំណឹង ឯកសារលេខ D11/2/3 ចុះថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១១ ដែលបញ្ជូនមកដោយមន្ត្រីទទួលបន្ទុកកិច្ចការសំណុំរឿង មកកាន់អង្គបុរេជំនុំជម្រះ ពាក់ព័ន្ធនឹងដីកាកែប្រែ។

[៣២] ទម្រង់បែបបទណែនាំស្តីពីការដាក់ឯកសារ ដែលបានប្រើប្រាស់ដើម្បីជូនដំណឹងអំពីដីកាកែប្រែ ហាក់ដូចជាទម្រង់បែបបទ ដែលបានចេញ ពាក់ព័ន្ធនឹងដីកាដែលត្រូវបានជំទាស់។ ក្រោយពីបានដាក់សំណើសុំ អង្គបុរេជំនុំជម្រះបានទទួលពីមន្ត្រីទទួល បន្ទុកកិច្ចការសំណុំរឿង នូវទម្រង់បែបបទណែនាំស្តីពីការដាក់ឯកសារសម្រាប់ដីកាកែប្រែ ដែលមានលក្ខណៈដូចគ្នាបេះបិទទៅ នឹងទម្រង់បែបបទ សម្រាប់ដីកាដែលត្រូវបានជំទាស់។ ទម្រង់បែបបទនេះណែនាំឲ្យធ្វើការជូនដំណឹងទៅការិយាល័យសហ ចៅក្រមស៊ើបអង្កេត និងសហព្រះរាជអាជ្ញាតែប៉ុណ្ណោះ ព្រមទាំងឲ្យជូនដំណឹងទៅលោក Hamill (ការណែនាំអំពីការដាក់ ឯកសារ និងការជូនដំណឹងលើឯកសារលេខ D11/2/3 ចុះថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១១ ដែលបានបញ្ជូនដោយមន្ត្រីទទួលបន្ទុក កិច្ចការសំណុំរឿង ជូនទៅអង្គបុរេជំនុំជម្រះពាក់ព័ន្ធនឹងដីកាកែប្រែ)។ ការបញ្ជាក់ថាបានទទួលបានការជូនដំណឹង ដែលបាន ចុះហត្ថលេខាដោយផ្នែកសេវាទូទៅរបស់តុលាការនេះ (ផ្នែកសេវាទូទៅ) បានលើកឡើងថា នៅថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០១១ បានទទួលការជូនដំណឹងអំពី "ដីកាសម្រេចស្តីពីភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ Rob Hamill លេខ ឯកសារលេខ D11/2/3 (អង់គ្លេស)"។ ការជូនដំណឹងនេះរួមមានកំណត់សម្គាល់ជាសំណេរលាយលក្ខណ៍អក្សរថា "GD 996 064 755 WW" (ការបញ្ជាក់ថាបានទទួលបានការជូនដំណឹង ចុះហត្ថលេខាដោយ កាន់ សិរីមុនី បុគ្គលិកផ្នែក សេវាទូទៅ ចុះថ្ងៃ ១១ ខែ កក្កដា ឆ្នាំ ២០១១)។ បញ្ជាទិញរបស់ក្រុមហ៊ុន TNT ដែលបានចុះហត្ថលេខាដោយមន្ត្រីទទួលបន្ទុក កិច្ចការសំណុំរឿង រួមមានហត្ថលេខាចំនួន ២៖ ហត្ថលេខាមួយចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១១ និងមួយទៀតចុះថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០១១។ នៅលើក្រដាសនៃក្រុមហ៊ុន TNT ពុំមានហត្ថលេខាបញ្ជាក់ថាបានទទួលបានឯកសារឡើយ។ របាយការណ៍ បញ្ជូនដោយក្រុមហ៊ុន TNT មានភាពខុសគ្នា ហើយមិនអាចបញ្ជាក់បានថា លោក Hamill បានទទួលដីកាកែប្រែនោះឡើយ។ ជាពិសេស ចំពោះការចូលមកដល់ចុងក្រោយគេ របាយការណ៍នេះរួមមាន "ទំនិញ បានមកដល់នៅក្នុងឃ្លាំងនៅម៉ោង ២៣:៣៩:៤៩ ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០១១"។ ក៏ប៉ុន្តែ នៅក្បាលទំព័រ របាយការណ៍នេះបានលើកឡើងថា ដីកាកែប្រែបាន បញ្ជូនទៅនៅថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០១១ នៅវេលាម៉ោង ០៨:៤០។ គួរកត់សម្គាល់ផងដែរគឺថា សម្ភារៈនៅក្នុងដៃគយនៅ ឡើយទេនៅវេលាម៉ោង ១០:៣០ ព្រឹក គឺក្រោយពេលមានការអះអាងថា បានបញ្ជូនចេញរួចហើយ។ របាយការណ៍ស្តីពីការបញ្ជូន ទំនិញរបស់ក្រុមហ៊ុន TNT ក៏មិនបានបង្ហាញបន្ថែមទៀតថា ដីកានេះបញ្ជូនទៅបុគ្គលណា ហើយក៏មិនបានបញ្ជាក់អាសយដ្ឋាន ណាមួយផងដែរ។ របាយការណ៍គ្រាន់តែបានបង្ហាញថា "ហត្ថលេខាទទួល: CD5718174" ដែលមិនបានបង្កើតជាភស្តុតាងថា លោក Hamill បានទទួលឡើយ ទោះក្នុងមធ្យោបាយណាក៏ដោយ។ ទោះបីជាការបញ្ជាក់ថាបានទទួលការជូនដំណឹង មានគោល បំណងបញ្ជាក់អំពីការទទួលបានការជូនដំណឹងអំពីឯកសារ ជូនទៅបុគ្គល ដែលត្រូវបានទទួលបានការជូនដំណឹងអំពីដីកានេះ ក៏ដោយ ក៏ការទទួលស្គាល់នៅក្នុងករណីនេះ ត្រឹមតែបង្ហាញថា ឯកសារនេះបានទទួលដោយ "អ្នករត់សំបុត្ររបស់ផ្នែកសេវា

ថ្ងៃទី ២៦ ខែ សីហា តែបានចុះកាលបរិច្ឆេទថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១១ វិញ ហើយពុំបានជូនដំណឹងដល់អង្គបុរេជំនុំជម្រះ ម្ចាស់បណ្តឹងឧទ្ធរណ៍ ឬមេធាវីរបស់គាត់ទេ។

១៤. យើងកត់សម្គាល់ឃើញថា ការកែប្រែទាំងនេះ មានគោលបំណងដោយមិនសមហេតុផល ដើម្បីជួសជុលវិការៈសំខាន់ៗនានា នៅក្នុងដីកាដែលត្រូវបានជំទាស់ ដែលបានបដិសេធចោលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង ០០៤ ក្រោយពីការពិចារណាលើដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរដែលបានដាក់នៅក្នុងរឿងក្តីនេះ ពោលគឺ មិនបានសម្រេចលើពាក្យសុំដែលបានដាក់នៅក្នុងសំណុំរឿង ០០៣ ឡើយ។ វិការៈទាំងនេះមួយចំនួន បានគូសបង្ហាញនៅក្នុងបណ្តឹងឧទ្ធរណ៍នេះ។ ការកែប្រែលើដីកាដែលត្រូវបានជំទាស់ មានសារៈសំខាន់ខ្លាំងណាស់ ដែលធ្វើឱ្យប៉ះពាល់ដល់ខ្លឹមសារនៃដីកានេះ។ នៅពេលពិចារណាលើការផ្លាស់ប្តូរដីកា ដែលបានធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេត សហចៅក្រមស៊ើបអង្កេតក៏ប្រាកដជាបានពិចារណាលើវិការៈសំខាន់ៗទាំងនេះផងដែរ ដោយហេតុយើងពិនិត្យឃើញថា សហចៅក្រមស៊ើបអង្កេតបានដាក់កាលបរិច្ឆេទលើដីកាកែប្រែនេះ ត្រឡប់ថយក្រោយ ហើយបានចុះហត្ថលេខាដោយដាក់កាលបរិច្ឆេទដូចគ្នាទៅនឹងកាលបរិច្ឆេទនៃដីកាដែលត្រូវបានជំទាស់ ដែលជាដីកាដំបូង ចេញដោយសហចៅក្រមស៊ើបអង្កេតខ្លួនឯង។ ការកែប្រែទាំងនេះ មិនអាចធ្វើឡើងតាមមធ្យោបាយកែតម្រូវបែបនេះឡើយ ជាពិសេស នៅក្នុងករណីដែលបណ្តឹងឧទ្ធរណ៍ ត្រូវបានដាក់ប្តឹងប្រឆាំងនឹងដីកានេះ និងលើកឡើងវិការៈមួយចំនួន ដែលដីកាកែប្រែមានបំណងចង់ជួសជុលឡើងវិញ។ ហេតុដូច្នេះ ដីកាកែប្រែ

---

ទូទៅ" ដែលត្រឹមតែមានតួនាទីបញ្ជូនឯកសារនេះទៅតាមរយៈក្រុមហ៊ុន TNT ក្រោយពីមន្ត្រីទទួលបន្ទុកកិច្ចការសំណុំរឿងបានបំពេញបញ្ជាទិញរបស់ក្រុមហ៊ុន TNT តែប៉ុណ្ណោះ។ ឯកសារបែបនេះមិនអាចធ្វើជាភស្តុតាងបង្ហាញថា លោក Hamill បានទទួល*ការជូនដំណឹង* ឬ *បង្កាន់ដៃទទួល*ដីកាកែប្រែ នៅក្នុងកាលៈទេសៈ ដូចបានរៀបរាប់ខាងលើឡើយ។ ម្យ៉ាងវិញទៀត ផ្ទុយពីមាត្រា ១១.២ នៃសេចក្តីណែនាំអនុវត្តស្តីអំពីការដាក់ឯកសារនៅចំពោះមុខ អ.វ.ត.ក និងទម្រង់បែបបទ អមជាមួយនឹងសេចក្តីណែនាំអនុវត្ត ក្រឡាបញ្ជី និងមន្ត្រីដែលទទួលការចាត់តាំងពីផ្នែកគ្រប់គ្រងគុណភាព ត្រូវបញ្ជាក់ថាបានជូនដំណឹង ក្រោយ "អ្នកទទួល" មិនមែនក្រោយអ្នករត់សំបុត្រផ្ញើក្នុងនោះទេ។ ជារួមមក នីតិវិធីនៃការជូនដំណឹង ដែលបានអនុវត្តពាក់ព័ន្ធនឹងដីកាកែប្រែ មិនអាចឱ្យយើងបញ្ជាក់ ឬ ផ្ទៀងផ្ទាត់បានថា លោក Hamill ពិតជាបានទទួលដីកាកែប្រែនេះឡើយ។ ដើម្បីបញ្ជាក់ឱ្យបានច្បាស់លាស់ និងដោយសារឯកសារពាក់ព័ន្ធនឹងការជូនដំណឹងពុំមែនជាផ្នែកមួយនៃសំណុំរឿង យើងសូមដាក់ភ្ជាប់ឯកសារទាំងនេះអមមកជាមួយនឹងមតិយោបល់របស់យើង។

ត្រូវតែចាត់ទុកថាជាដីកាមួយខុសទាំងស្រុងទៅនឹងដីកាដែលត្រូវបានជំទាស់ ដែលត្រូវបានដកចេញពីក្នុងសំណុំរឿង ហើយក្រោយមកយកដីកាថ្មីមួយមកជំនួសវិញ។ ផលវិបាកកើតចេញពីករណីនេះគឺថា ដីកាដែលត្រូវបានជំទាស់ លែងមានអត្ថិភាពទៀតហើយ។

១៥. ដោយហេតុថា បណ្តឹងឧទ្ធរណ៍បានប្តឹងនឹងដីកាដែលត្រូវបានជំទាស់ ដែលនៅពេលនោះ ដីកាកែប្រែពុំទាន់ទាំងមានអត្ថិភាពនៅឡើយទេ បណ្តឹងឧទ្ធរណ៍នេះ អាចយកមកពិចារណាបាន ដោយពាក់ព័ន្ធទៅនឹងដីកាដែលត្រូវបានជំទាស់តែប៉ុណ្ណោះ។ យើងយល់ឃើញថា បណ្តឹងឧទ្ធរណ៍នេះ ពុំមានន័យខ្លឹមសារអ្វីឡើយ ដោយហេតុថា ដីកាដែលត្រូវបានជំទាស់លែងមានអត្ថិភាពទៀតហើយ។ យើងក៏សូមបញ្ជាក់ថែមទៀតដែរថា វាមិនអាចធ្វើទៅបាន និងរំលោភទៅលើសិទ្ធិរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ បើសិនជាសម្រេចទៅលើបណ្តឹងឧទ្ធរណ៍ដោយផ្អែកទៅលើដីកាដែលត្រូវបានកែប្រែ ពីព្រោះថា គ្មានភស្តុតាងនៃការជូនដំណឹងអំពីដីកាដែលត្រូវបានកែប្រែនេះចំពោះគាត់ ឬមេធាវីរបស់គាត់ ដើម្បីឱ្យគាត់អាចឆ្លើយតបទៅនឹងដីកាដែលត្រូវបានកែប្រែនេះទេ។ ទោះបីជាយ៉ាងនេះក្តី យើងកត់សម្គាល់ឃើញថា ចាប់ពីមានការជូនដំណឹងអំពីដីកាកែប្រែនេះទៅម្ចាស់បណ្តឹងឧទ្ធរណ៍ និងមេធាវីតំណាងឱ្យគាត់ ភាគីនឹងមានសិទ្ធិធ្វើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាកែប្រែនេះ។ យើងបានដាក់ដីកាកែប្រែនេះជាភាសាអង់គ្លេស (ឧបសម្ព័ន្ធ ក) និងជាភាសាខ្មែរ (ឧបសម្ព័ន្ធ ខ) និងទម្រង់បែបបទសុំកែប្រែ ចុះថ្ងៃទី ៦ ខែ កក្កដា ឆ្នាំ ២០១១ (ឧបសម្ព័ន្ធ គ) និងថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០១១ (ឧបសម្ព័ន្ធ ឃ) អមមកជាមួយមតិយោបល់របស់យើង ដើម្បីចាត់ទុកជាការជូនដំណឹងឱ្យបានត្រឹមត្រូវអំពីដីកានេះ ដល់ម្ចាស់បណ្តឹងឧទ្ធរណ៍ និងមេធាវីរបស់គាត់។ យើងក៏បានដាក់អមមកជាមួយនូវឯកសារទាំងឡាយដូចខាងក្រោម ដែលឯកសារទាំងនេះមានសារៈសំខាន់ចំពោះការស្វែងយល់លើសេចក្តីសន្និដ្ឋានរបស់យើងថា ដីកាកែប្រែមិនបានជូនដំណឹងឱ្យបានត្រឹមត្រូវដល់ម្ចាស់បណ្តឹងឧទ្ធរណ៍ និងមេធាវីរបស់គាត់ ដោយសារគ្មាននរណាម្នាក់ក្នុងចំណោមអ្នកទាំងនេះមានសិទ្ធិពិនិត្យសំណុំរឿងឡើយ។ ឯកសារទាំងនេះរួមមាន ង) សេចក្តីណែនាំស្តីពីការដាក់ឯកសារ និងការជូនដំណឹង ឯកសារលេខ D11/2/3 ចុះថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១១ ដែលមន្ត្រីទទួលបន្ទុកកិច្ចការសំណុំរឿងបានបញ្ជូនមកអង្គបុរេជំនុំជម្រះ ពាក់ព័ន្ធនឹងដីកាកែប្រែ ច) ការទទួលស្គាល់ថាបានទទួលការជូនដំណឹង ដែលបានចុះហត្ថលេខាដោយ កាន់ សិរីមុនី បុគ្គលិកមកពីផ្នែកសេវាទូទៅ

ចុះថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០១១ ឆ) បញ្ជាទិញនៃក្រុមហ៊ុន TNT លេខ GD 996 064 755 WW និង ជ) របាយការណ៍បញ្ជូនទំនិញរបស់ក្រុមហ៊ុន TNT។ យើងកត់សំគាល់បន្ថែមទៀតថា ដោយសារតែកំហុសនីតិវិធីទាំងអស់បានកើតមាននៅក្នុងសំណុំរឿងនេះ សហចៅក្រមស៊ើបអង្កេតគួរពិចារណាឡើងវិញ ឲ្យបានច្បាស់លាស់ចំពោះពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ បន្ទាប់ពីអនុវត្តតាមនីតិវិធីសមស្រប។

១៦. នៅក្នុងកាលៈទេសៈដែលយើងបានលើកឡើងរួចនោះ យើងគិតថា យើងមិនអាចធ្វើការពិភាក្សាអំពីអង្គសេចក្តីនៃបណ្តឹងឧទ្ធរណ៍បានទេ។ យ៉ាងណាក៏ដោយ យើងកត់សំគាល់ឃើញថា បញ្ហាទាំងអស់ដែលត្រូវបានលើកឡើងនៅក្នុងបណ្តឹងឧទ្ធរណ៍ នឹងត្រូវពិចារណា មុនពេលចៅក្រមឈានទៅសន្និដ្ឋានថា សិទ្ធិរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍មិនត្រូវបានរំលោភបំពាន ដោយសារការបដិសេធពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។ យើងក៏បានពន្យល់រួចហើយនៅក្នុងមតិយោបល់របស់យើងពីមុន ស្តីពីការខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញាចំពោះបញ្ហាថាតើដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរទីពីរនេះ គួរ ឬពុំគួរដាក់។ យើងគិតថា នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរមានអង្គហេតុថ្មី[៣៣]។ ទោះក្នុងករណីណាក៏ដោយ យើងយល់ថា ការគ្មានអង្គហេតុថ្មី មិនមានឥទ្ធិពលទៅលើការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អនុលោមតាមវិធាន ២៣ *ស្ទួន* នៃវិធានផ្ទៃក្នុងទៀតហើយ ដោយសារតែមានការបើកកិច្ចស៊ើបសួរទៅលើអង្គហេតុដែលមានរៀបរាប់ក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរទីពីរ។ លើសពីនេះ ទោះបីជាយើងពិចារណាឃើញថា សហចៅក្រមស៊ើបអង្កេតមានឆន្ទានុសិទ្ធិសម្រេចលើពេលវេលាក្នុងការចោទប្រកាន់ជាផ្លូវការលើជនដែលស្ថិតនៅក្រោមការចោទប្រកាន់ក៏ដោយ សហចៅក្រមស៊ើបអង្កេតមិនផ្តល់សំអាងហេតុនៃការធ្វើដូច្នេះ បន្ទាប់ពីបើកកិច្ចស៊ើបសួរ ដោយសារសហចៅក្រមបានធ្វើដូច្នេះ នៅក្នុងសំណុំរឿង ០០១ និង ០០២។ ដូច្នេះ យើងពិចារណាឃើញថា សហចៅក្រមស៊ើបអង្កេត មានកាតព្វកិច្ចសម្រេចលើខ្លឹមសារនៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅពេលខ្លួនទទួលបាន

---

[៣៣] ករណីខ្វែងយោបល់ លេខ៖ ០០១/១៨-១១-២០០៨-អវតក/អបជ សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះលើករណីខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៧១ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០០៩ មតិយោបល់របស់ចៅក្រម Lahuis និងចៅក្រម Downing ។

ពាក្យសុំទាំងនេះ។ សហចៅក្រមស៊ើបអង្កេតហាក់ដូចជាយល់ឃើញដូចគ្នា នៅពេលគាត់ពិនិត្យ និងសម្រេចលើអង្គសេចក្តីនៃពាក្យសុំរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍។ អាស្រ័យហេតុនេះ នៅពេលដែលពុំទាន់មានព័ត៌មាន ចាំបាច់សម្រាប់យកមកវាយតម្លៃលើខ្លឹមសារនៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងរឿងក្តីនៅចំពោះមុខ អ.វ.ត.ក សហចៅក្រមស៊ើបអង្កេត ឬ អង្គបុរេជំនុំជម្រះ គួរច្រានចោលសេចក្តីសម្រេចរបស់ខ្លួនលើបញ្ហានេះ ដោយរង់ចាំរហូតដល់ពេលមានព័ត៌មានទាំងនោះ នៅក្នុងអំឡុងពេលស៊ើបសួរជាមុនសិន ដែលជាលក្ខខណ្ឌមានចែងនៅក្នុងវិធានផ្ទៃក្នុង។ ការធ្វើចំណាត់ការណាមួយផ្សេងពីនេះ នឹងនាំឲ្យការបដិសេធលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ជាការធ្វើឡើងមុនដំណាក់កាលនៃនីតិវិធី ហើយបានធ្វើឲ្យប៉ះពាល់ដល់ប្រព័ន្ធទទួលស្គាល់ដើមបណ្តឹងរដ្ឋប្បវេណីទាំងមូលតែម្តង ដែលប្រព័ន្ធនេះបានបង្កើតឡើងសម្រាប់ជនរងគ្រោះ ស្របតាមវិធានផ្ទៃក្នុងនៃ អ.វ.ត.ក។

ធ្វើនៅភ្នំពេញ ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១១

PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE
E.C.C.C • C.E.T.C

ចៅក្រម Rowan DOWNING ចៅក្រម Katinka LAHUIS